# កម្ពុជាក្រោម

ព្រឹត្តិបត្រពោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៧ ឆ្នាំទី ០២ – ខែឧសភា គ.ស. ២០០៥ – ព.ស. ២៥៤៩ – N$^0$ 17, May, 2005


# ស្ថានភាពជនជាតិទួកម៉ែននៅប្រទេសអ៊ីរ៉ាក់ ជនជាតិអាបរាហ្សី និងជនជាតិខ្មែរក្រោម បានលាតត្រដាងបង្ហាញអង្គការ UNCHR

*សេចក្ដីថ្លែងការរបស់លោក ថាច់ ង៉ុក ថាច់ ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងទៅកាន់សហព័ន្ធអន្តរជាតិដើម្បីការពារសិទ្ធិក្រុមជាតិពន្ធុ សាសនា ភាសា និង ជនជាតិភាគតិច នាសម័យប្រជុំលើកទី ៦១ នៅទីក្រុងហ្សឺណែវ ចាប់ពីថ្ងៃទី ១៤ មីនា ដល់ថ្ងៃទី ២២ មេសា ២០០៥ ។*

*លោកប្រធានជាទីគោរព* !

សូម្បីតែជនជាតិទួកម៉ែន ដែលតំណាងឲ្យសហគមន៍ដ៏ធំមួយនេះ ក៏ពួកគេនៅតែទទួលរងនូវការធ្វើទុក្ខបុកម្នេញពីសំណាក់គោលនយោបាយជ្រៀតជ្រែកគ្រប់លំដាប់ថ្នាក់ និងពុំសូវបានទទួលនូវសេរីភាព និងសិទ្ធិមនុស្សជាមូលដ្ឋានសោះឡើយ ។ ជនជាតិទួក–ម៉ែន មានក្ដីសង្ឃឹមថានឹងដល់ពេលវេលាត្រូវបញ្ចប់អំពើហិង្សា និងបទឧក្រិដ្ឋកម្មទាំងឡាយមកលើភាសា និង សិទ្ធិវប្បធម៌របស់ជន–ជាតិភាគតិចហើយ ក្នុងពេលដែលកងកម្លាំងសហរដ្ឋអាមេរិកបានចូលទៅក្នុងប្រទេសអ៊ីរ៉ាក់ កាលពីពីរឆ្នាំកន្លងទៅនេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏គោលនយោបាយឧក្រិដ្ឋកម្មថ្មី ៗ នេះ កំពុងបង្កឡើងប្រឆាំងនឹងជនជាតិទួកម៉ែន ចេះតែត្រូវបានគេប្រព្រឹត្តជាហូរហែរ ។

## មាតិការឿង


–ស្ថានភាពជនជាតិទួកម៉ែននៅប្រទេសអ៊ីរ៉ាក់ ជនជាតិអាបរាហ្សី និងជនជាតិខ្មែរក្រោម.....១
–តំណាងសហព័ន្ធអញ្ជើញចូលរួមជាវាគ្មិន នៅសាកលវិទ្យាល័យរោវ័ណ..........៣
–និស្សិតខ្មែរកម្ពុជាក្រោមទទួលអំណរឆ្នាំថ្មី..........៣
–ភាពក្រីក្រកំពុងគំរាមកំហែងប្រជារាស្ត្រខ្មែរភូមិស្លាប៉ាង..........៥
–អតីតព្រះរាជាលាតត្រដាង កម្ពុជាក្រោម–ព្រៃនគរ–កោះត្រល់..........៦
–រឿងកំពប់តែអុង..........៧
–អ្នកតាបាពាល ឬ ព្រះកន្លោង..........១០
–កំណាព្យទឹកភ្នែកខ្មែរក្រោម..........១១
–វេទិកាគំនិតជាតិ..........១២
–រឿងកនកវណ្ណរាជ..........១៥




*លោក ថាច់ ង៉ុក ថាច់ ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម*

វិធានការដំបូងនៃកងកម្លាំងដែលនាំមុខដោយសហរដ្ឋអាមេរិក ចូលក្នុងប្រទេសអ៊ីរ៉ាក់ បានធ្វើឲ្យជនជាតិឃឺត ត្រូវបានគេតែងតាំង និងលើកស្ទួយក្នុងតួនាទីជាមន្ត្រីផ្លូវការសំខាន់ ៗ ជាច្រើនរូប ព្រមទាំងមានការកែប្រែមុខមាត់ជនជាតិឃឺតជាច្រើនផ្សេងទៀត ក្នុងលទ្ធិភាពសាសនាឃឺតយុត និងទួកម៉ែន កាលពីមុនពេលបោះឆ្នោត នាខែមេសា ឆ្នាំ ២០០៥ នោះ ។

ជនជាតិទួកម៉ែន តែងតែប្រាថ្នារួមរស់ក្នុងសន្តិភាពជាមួយប្រជាជនអារ៉ាប់ ប្រជាជនឃឺត ក៏ដូចជាប្រជាជនខាលដូអាស៊ីរៀនរបស់ពួកគេ ក្នុងការទទួលបានសិទ្ធិសេរីភាពក្នុងប្រទេសអ៊ីរ៉ាក់ដែលជាកន្លែងមានប្រជាពលរដ្ឋ និង សាសនាផ្សេងទៀត ដែលមិនត្រូវបានអ្នកណាមួយគិតគូរដល់ទាល់តែសោះ ឲ្យមានសិទ្ធិសេរីភាពស្មើ ៗ គ្នាទាំងក្នុងការរស់នៅ ទាំងក្នុងការចែកចាយទ្រព្យសម្បត្តិប្រេងក្នុងប្រ–ទេសខ្លួន ឲ្យបានស្មើគ្នាទៅនឹងប្រជាពលរដ្ឋអ៊ីរ៉ាក់គ្រប់រូបដែរ។

*លោកប្រធានជាទីគោរព* ! អង្គការរបស់យើងខ្ញុំ សូមអំពាវ–នាវដល់គណៈកម្មការ មេត្តាជួយចាត់ចូលជារបាយការណ៍សំខាន់ ៗ ស្ដីពីស្ថានភាពរបស់ជនជាតិទួកម៉ែន និង ព្រមទាំងទទូចសុំឲ្យបេស–កជនជាន់ខ្ពស់ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ជួយឃ្លាំមើលការរំលោភ



សិទ្ធិមនុស្ស ដែលមានមកលើជនជាតិទូកម៉ែន ។

*លោកប្រធានជាទីគោរព* ! សព្វថ្ងៃនេះ ជនជាតិទីបេ កំពុងតែក្លាយខ្លួនឯងទៅជាជនជាតិភាគតិចយ៉ាងឆាប់រហ័ស ក្នុងមាតុភូមិរបស់ខ្លួន ដោយនយោបាយបញ្ជូនមនុស្សមកតាំងទីលំនៅថ្មីជាច្រើន ចំពេលដែលជនជាអាបវាហ្សី ដែលរស់នៅក្នុងតំបន់ភូមិភាគខាងត្បូងឈាងខាងលិចនៃប្រទេសអ៊ីរ៉ង់ ក្នុងទស្សនៈមួយធ្វើខ្លួនឯងថាជាជនបរទេសក្នុងមាតុភូមិរបស់ពួកខ្លួន ។ ពួកជនជាតិអាបវាហ្សី តែងតែទទួលការលុបបំបាត់ នូវអត្តសញ្ញាណជាតិ វប្បធម៌ ភាសា និងប្រពៃណីរបស់ផងខ្លួន ដោយប្រតិបត្តិតាមបទគ្រប់គ្រងអំណាចសព្វ–ថ្ងៃក្នុងប្រទេសអ៊ីរ៉ង់ មិនតែប៉ុណ្ណោះក៏ត្រូវប្រឈមមុខនឹងការរស់នៅដោយការទាក់ទាញទាំងបង្ខំ និងដោយការដាក់កម្រិតពន្ធដា តាមរយៈភាសា និងវប្បធម៌នៃជនជាតិផើស៊ីន ។ យើងខ្ញុំសូមអំពាវនាវមកក្នុងអាណត្តិកាលនៃគណៈកម្មការតាមរយៈប្រធានបទនេះ សូមមេត្តាជួយស៊ើបអង្កេតស្ថានការជនជាតិភាគតិច អាបវាហ្សី–អារ៉ាប់ ក្នុងទឹកដីអ៊ីរ៉ង់ ។ ម្យ៉ាងទៀត សូមមេត្តាជួយគិតគូរពីសុវត្ថិភាព និងសន្តិសុខរបស់ពួកគេផង ដែលបានភៀសខ្លួនដោយបុព្វហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញគ្រប់ទិដ្ឋភាព ពីសំណាក់រដ្ឋាភិបាលអ៊ីរ៉ង់អស់ពីរទសវត្សកន្លងទៅនេះ ។

*លោកប្រធានជាទីគោរព* ! សូមមេត្តាលោកប្រធានជួយពិចារណាផងមើល ទៅលើរបាយការណ៍ជាលើកទីពីររបស់វៀតណាម ដែលគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ហៅកាត់ថា (HRC) បានស្នើសុំឲ្យវៀតណាមផ្តល់ព័ត៌មានស្តីពីជនជាតិភាគតិច ដែលកំពុងកើតមានក្នុងប្រទេសនេះ រាប់បញ្ចូលទាំងសហាគមន៍ខ្មែរ–ក្រោមដ៏ធំមួយក្នុងនោះផងដែរ ។ ជាការឆ្លើយតបរបស់វៀតណាម ជូនមកអង្គការ HRC វិញថា ខ្លួនសន្យានឹងត្រូវផ្តល់ជូន ប៉ុន្តែទង្វើទាំងអស់ខាងលើជាការផ្ទុយស្រឡះពីស្ថានភាពពិត ដែលបានកំពុងកើតមានមកលើប្រជាជាតិខ្មែរកម្ពុជាក្រោមជាវិជ្ជមាន ។ យើងខ្ញុំមានកង្វល់ជាខ្លាំងណាស់ ដែលប្រជាពលរដ្ឋខ្មែរក្រោម គឺជាជនជាតិភាគតិច ងាយត្រូវគេធ្វើបាបតាមរយៈប្រព័ន្ធសេវាសុខភាពគ្រប់លំដាប់ជំងឺ ដែលពួកគេកំពុងទទួលរងទុក្ខផ្នែកសុខមាលភាពដ៏ធ្ងន់ធ្ងរជាមួយនិងនយោបាយរំលាយពូជសាសន៍របស់ពួកគេ ។ ដូចជាករណីជម្ងឺខ្វាក់ភ្នែក ចាប់តាំងពី ២០០៣ មកម្ល៉េះ គ្មានការព្យាបាលថែទាំណាមួយឲ្យបានត្រឹមត្រូវ សមរម្យអ្វីសោះទេ ។ ជម្ងឺនេះបានរាលដាលនិងជះឥទ្ធិពល ទៅដល់ប្រជាជាតិខ្មែរកម្ពុជាក្រោមរាប់ពាន់នាក់ ។ វៀតណាមបាន លាក់កំបាំងកប់ទុកចោលយ៉ាងជ្រៅនូវបញ្ហាទាំងនេះ ហើយបានយកឱកាសនេះ ដើម្បីពិសោធស្វែងរកពីមូលហេតុ និងរុករកឱសថទៅវិញ ដោយមិនបានយកចិត្តទុកដាក់ចំពោះអ្នកទាំងនោះសោះ ។ អង្គការរបស់យើងខ្ញុំ តែងតែសុំអំពាវនាវមកដល់អាណត្តិនៃគណៈកម្មការ តាមរយៈប្រធានបទខ្លីនេះ ដើម្បីស្វែងរកសកម្មជនចំណាន ៗ ឲ្យអញ្ជើញទៅក្នុងតំបន់ដែលមានខ្មែរកម្ពុជា–ក្រោមកំពុងរស់នៅសព្វថ្ងៃ ។

*លោកប្រធានជាទីគោរព* ! ប្រជាជាតិខ្មែរកម្ពុជាក្រោម និងព្រះសង្ឃខ្មែរក្រោម ដែលមកពីប្រទេសកម្ពុជា កំពុងតែប្រឈមមុខនឹងការធ្វើទុក្ខបុកម្នេញ រំលោភបំពានដ៏ធ្ងន់ធ្ងរ ក្នុងពេលដែលពួកគេវិលត្រឡប់មកស្រុកកំណើតវិញ ។ សិទ្ធិជាជនជាតិភាគតិច ដែលត្រូវគេទទួលស្គាល់តាមស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ មិនត្រូវបានវៀតណាមគោរពបន្តិចសោះឡើយ ។ វត្តអារាមព្រះពុទ្ធសាសនា បានត្រូវគេបំផ្លាញចោលបណ្តើរ ៗ ហើយ ។ ព្រះសង្ឃយើងខ្ញុំត្រូវបានគេចាប់ដាក់គុក និងធ្វើឃាតផងដែរ ។ កម្មវិធីបុណ្យទាន ប្រពៃណីសាសនា ក៏ត្រូវគេហាមឃាត់ អ្នកទាំងនោះសុទ្ធសឹងតែមានប្រាថ្នាដើម្បីអនុវត្តឲ្យចំទ្រីស្តីព្រះពុទ្ធសាសនា ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមក៏មានកិត្តិយសដូចជាមនុស្សជាតិដ៏ទៃទៀតដែរ ហេតុអ្វីត្រូវបានជាតិ–សាសន៍មួយជាន់ឈ្លីតាមចិត្តទៅវិញ ។ កុមារា កុមារី របស់ពួកយើងខ្ញុំបានទទួលរងគ្រោះពីពលកម្មកុមារ ការជួញដូរមនុស្ស និងពេស្យាកម្ម កង្វះខាតចំណីអាហារ កង្វះខាតថ្នាំពេទ្យ និងប្រព័ន្ធអប់រំ និងការងារ ។

យើងខ្ញុំសូមអំពាវនាវមកដល់គណៈកម្មការ សូមមេត្តាចាត់ចូលជារបាយការណ៍ដ៏សំខាន់នៃស្ថានភាពសិទ្ធិមនុស្ស ដែលបានលើកយកមកបង្ហាញត្រួស ៗ ក្នុងសេចក្តីថ្លែងការនេះ ហើយសូមអំពាវនាវមកបេសកជនសិទ្ធិមនុស្សជាន់ខ្ពស់ សូមឲ្យចាត់វិធានការជាបន្ទាន់ ក្នុងការជួយស្រោចស្រង់ស្ថានភាពរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនេះ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកប្រធាន ៕

និពន្ធនាយក ៖ **ថាច់ ប៉ុកថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

## ព័ត៌មាន

# តំណាងសហព័ន្ធអញ្ជើញចូលរួមជាវាគ្មិន នៅសាកលវិទ្យាល័យរោវ័ណ




Mr. Craig Katz, *លោក ត្រឹង យ៉ាប, លោក យីប ខា និងលោក ថាច់ លែន*

តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានលោក ត្រឹង យ៉ាប, លោក យីប ខា និង លោក ថាច់ លែន បានជួបពិភាក្សា ជាមួយថ្នាក់ដឹកនាំមហាវិទ្យាល័យ និងថ្លែងទៅកាន់និស្សិតផ្នែកសិក្សាអន្តរជាតិ នៃសាកលវិទ្យាល័យរោវ័ណ នៅទីក្រុង ហ្គ្លាស្សប្បូរ (Glassboro) រដ្ឋញ៊ូវជើស៊ី (New Jersey) សហរដ្ឋអាមេរិក កាលពីថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៥ ។

លោក ត្រឹង យ៉ាប បានឆ្លៀតឱកាសនេះ លើកឡើងនូវប្រធានបទស្តីអំពីលទ្ធភាព នៃការផ្លោះប្តូរនិស្សិតខ្មែរកម្ពុជាក្រោមនៅសាកលវិទ្យាល័យរោវ័ណ ។ ហើយចំណុចពិស្តារនឹងត្រូវបានពិភាក្សាក្នុងជំនួបពេលក្រោយទៀត ។

នៅក្នុងខ្លឹមទំនាក់ទំនងអន្តរជាតិ នៃសាកលវិទ្យាល័យរោវ័ណ លោក យីប ខា បានថ្លែងសង្ខេបអំពីប្រវត្តិសាស្ត្រខ្មែរកម្ពុជាក្រោម ទំនាក់ទំនងរវាងប្រទេសបារាំង កម្ពុជា និង យួន ក្នុងអតីតកាល ។ ហើយសុន្ទរកថាទាំងមូលរបស់លោក គឺសង្កត់ធ្ងន់ទៅលើការរំលោភសិទ្ធិមនុស្សកាលពីអតីត ក៏ដូចជាបច្ចុប្បន្ន ពីសំណាក់រដ្ឋាភិបាលយួន ដែលធ្វើឲ្យខ្មែរក្រោមត្រូវរងទុក្ខវេទនា ។ សុន្ទរកថារបស់លោក យីប ខា ទទួលបានការស្វាគមន៍យ៉ាងខ្លាំងក្លា ដែលគាត់បានពន្យល់សវនាករអំពីស្ថានភាពនៅកម្ពុជាក្រោម ដែលជនជាតិអាមេរិក មានការដឹងឮតិចតួចណាស់ ៕

# និស្សិតខ្មែរកម្ពុជាក្រោមទទួលអំណរឆ្នាំថ្មី



*ព្រះតេជគុណ យៀង វណ្ណា ប្រធានសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម*



*សមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម និងភ្ញៀវកិត្តិយស ក្នុងទីធ្លាវត្តសាមគ្គីរង្សី*

សមណនិស្សិត និងនិស្សិតខ្មែរក្រោម ប្រមាណ ៨០ អង្គ និងរូប បានរៀបចំពិធីជួបជុំគ្នាមួយ កាលពីថ្ងៃទី ១៣ មេសា ឆ្នាំ ២០០៥ នៅវត្តសាមគ្គីរង្សី រាជធានីភ្នំពេញ ដើម្បីទទួលអំណរឆ្នាំថ្មី ឆ្នាំរកា សប្តស័ក ព.ស. ២៥៤៩ ដោយមានការចូលរួមគាំទ្រពីសំណាក់ព្រះសង្ឃ និងគ្រហស្ថ ពីគ្រប់មជ្ឈដ្ឋានប្រមាណ ២០០ អង្គ និងរូបយ៉ាងអធិកអធមបំផុត ។

ឆ្នាំនេះជាឆ្នាំទី ៣ ហើយ ដែលសមណនិស្សិត និស្សិតមានដើមកំណើតខ្មែរកម្ពុជាក្រោមនៅកម្ពុជា បានរៀបចំពិធីជួបជុំគ្នាទទួលអណរឆ្នាំថ្មី ។ ក្នុងការរៀបចំពីធីជួបជុំទទួលអំណរឆ្នាំថ្មីរបស់និស្សិតខ្មែរកម្ពុជាក្រោម កាលពីពីរឆ្នាំបន្តបន្ទាប់មកនេះ ក៏បានប្រារព្ធឡើងនៅក្នុងបរិវេណវត្តសាមគ្គីរង្សីនេះដែរ តែសម្រាប់ការជួបជុំឆ្នាំនេះមានភាពអធិកអធមជាងបណ្តាឆ្នាំមុន ៗ ។ ក្នុងសុន្ទរកថាបើកកម្មវិធី ដែលថ្លែងដោយ ភិក្ខុ ចៅ សាង អនុប្រធានសម្ព័ន្ធសមណនិស្សិតនិស្សិតខ្មែរកម្ពុជាក្រោមបានឲ្យដឹងថា "ការជួបជុំគ្នានេះគឺជារបៀបវារៈមួយដែលអង្គការណាក៏ដោយតែងតែប្រារព្ធឡើង ដើម្បីជប់លៀងគ្នាសម្តែងនូវទឹកចិត្តសាមគ្គីគ្នា ប្តូរយោបល់គ្នា និងចែករំលែកចំណេះដឹង

ព្រមទាំងបទពិសោធន៍ដល់គ្នាទៅវិញទៅមក មុននឹងផ្អាកការងារសិក្សាមួយរយៈខ្លីដើម្បីរៀបចំខ្លួនទទួលអំណរឆ្នាំថ្មី ។ តាមរយៈសុន្ទរកថានេះដែរ ភិក្ខុ ថៅ សាង បានឲ្យដឹងថា “បច្ចុប្បន្ន សម្ព័ន្ធសមណនិស្សិត មានសមាជិករបស់ខ្លួនចំនួន ១៦២ រូប ក្នុងនេះមាននិស្សិតជាព្រះសង្ឃចំនួន ១៣២ ព្រះអង្គ និងគ្រហស្ថចំនួន ៣០ រូប ។ ក្នុងចំនួនសមាជិកទាំងនេះ មានសមាសភាពពីថ្នាក់បរិញ្ញាបត្រហូតដល់បណ្ឌិត ដែលអ្នកខ្លះ អង្គខ្លះ កំពុងបំពេញកម្មសិក្សានៅឯមាតុភូមិកម្ពុជាក្រោមកម្ពុជា នៅប្រទេសឥណ្ឌា សហភាពភូមា ព្រះរាជាណាចក្រថៃ និងនៅសហរដ្ឋអាមេរិកទៀតផង ។ ហើយចំនួននិស្សិតខ្មែរកម្ពុជាក្រោមនេះ មិនមែនមានតែប៉ុណ្ណោះទេ គឺនៅមានច្រើនទៀតដែលសម្ព័ន្ធសមណនិស្សិតកំពុង តែគៀងគរប្រមូលផ្ដុំឲ្យកាន់តែធំឡើងជាលំដាប់ ។

ភិក្ខុ ថៅ សាង បានបញ្ជាក់បន្ថែមឲ្យដឹងយ៉ាងនេះថា ៖ “សកម្មភាពរបស់សម្ព័ន្ធសមណនិស្សិត មិនត្រឹមតែបង្កើនចំណេះដឹងខ្លួនឯងប៉ុណ្ណោះទេ គឺកន្លងមកនេះ សម្ព័ន្ធសមណនិស្សិត បានបើកវគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីនូវចំណេះដឹងចាំបាច់ខ្លះ មានវគ្គតែងនិពន្ធកំណាព្យ វិជ្ជាជីវៈសារព័ត៌មាន និងនិពន្ធប្រលោមលោក ជាដើម” ដល់សមាជិករបស់ខ្លួន និងសមាជិកបណ្ដាអង្គភាពផ្សេង ៗ ទៀតនៃខ្មែរកម្ពុជាក្រោម ។ នៅលើវេទិកា ចំពោះមុខមិត្តរួមជំនាន់របស់ខ្លួន ចំពោះមុខភ្ញៀវកិត្តិយស ដែលចូលរួមគាំទ្រវាប់រយនាក់ ទាំងព្រះសង្ឃ និងគ្រហស្ថផងនោះ ក្នុងកាយពលរឹងមាំ ទឹកព្រះភ័ក្ត្រអង់អាចក្លាហាន ភិក្ខុ ថៅ សាង បានសង្កត់ធ្ងន់នូវតួនាទីរបស់និស្សិតថា “នឹងខិតខំរៀនសូត្រឲ្យមានចំណេះខ្ពង់ខ្ពស់ កសាងខ្លួនជាកុលបុត្រដ៏ល្អ ដើម្បីរំដោះជាតិមាតុភូមិឲ្យរួចផុតពីរបបអាណានិគម ឈានទៅដល់គោលដៅសម្រេចវាសនាខ្លួនដោយខ្លួនឯង សមតាមបំណងប្រាថ្នារបស់ខ្មែរក្រោមគ្រប់រូប ស្របតាមច្បាប់អង្គការសហប្រជាជាតិ ។

ព្រះភិក្ខុ ថៅ សាង ក៏ពុំបានភ្លេចផងដែរនូវការដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលមានការសន្ដោសប្រណីដល់ខ្មែរក្រោម ដល់សម្ព័ន្ធសមណនិស្សិតជារៀងរហូតមក ។

ក្នុងឱកាសនេះដែរ លោក តាំង សារៈ ដែលជាតំណាងសហព័ន្ធខ្មែរកម្ពុជាក្រោម បានកោតសរសើរចំពោះស្មារតីសាមគ្គីគ្នាដ៏អង់អាចក្លាហាន ចំពោះការរៀបចំពិធីជួបជុំគ្នា និងចំពោះការខិតខំរៀនសូត្ររបស់សម្ព័ន្ធសមណនិស្សិតខ្មែរកម្ពុជាក្រោម ។ លោក តាំង សារៈ បានបញ្ជាក់ពីគោលជំហរ និងទិសទៅរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមឲ្យដឹងថា “សហព័ន្ធខ្មែរកម្ពុជាក្រោម ជាសមាជិកអង្គការ UNPO សហព័ន្ធខ្មែរកម្ពុជាក្រោម មិនទាមទារនូវទឹកដីកម្ពុជាក្រោមមកវិញទេ ព្រោះទឹកដីកម្ពុជាក្រោមនៅតែស្ថិតនៅកម្ពុជាក្រោមដដែល ឯការបាត់នោះ គឺខ្មែរក្រោមបាត់បង់នូវសិទ្ធិជាម្ចាស់នៃទឹកដីកម្ពុជាក្រោម ហេតុនេះខ្មែរក្រោមទាមទារហើយទាមទារទៀត ដោយសន្តិវិធី និងអហិង្សាស្របតាមច្បាប់អង្គការ UNPO អង្គការសហប្រជាជាតិ រហូតទាល់តែបានទទួលសិទ្ធិពេញលេញជាម្ចាស់ដើម នៃទឹកដីកម្ពុជាក្រោម ។ ហើយលោក តាំង សារៈ ក៏បានអង្វរកដល់ខ្មែរក្រោមគ្រប់រូបនៅកម្ពុជាយ៉ាងដូច្នេះថា “ទិសដៅរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម គឺឈានទៅសកម្មភាព និងដំណោះស្រាយនៅឯមាតុភូមិកម្ពុជាក្រោម ហេតុនេះ សូមបងប្អូនខ្មែរក្រោមនៅកម្ពុជា កុំបង្កផលវិបាកអ្វីមួយដល់កម្ពុជាឲ្យសោះ” ។

បន្ទាប់ពីចំណាប់អារម្មណ៍របស់លោក តាំង សារៈ មក កញ្ញា សឺន បុប្ផា ដែលមានទឹកមុខស្រស់ប្រិមប្រិយ សុភាពរាបសារ បានឡើងទៅកាន់វេទិកា ក្នុងនាមតំណាងឲ្យនិស្សិតខ្មែរកម្ពុជាក្រោម ថ្លែងទៅកាន់ព្រះសង្ឃ និងភ្ញៀវទាំងអស់នូវការដឹងគុណ ចំពោះវត្តមានដ៏ថ្លៃថ្លារបស់ព្រះសង្ឃ និងភ្ញៀវគ្រប់រូបដែលបានចូលរួមក្នុងអង្គពិធីនេះ ។ កញ្ញា បុប្ផា ក៏បានកោតសរសើរផងដែរ ចំពោះការខិតខំតស៊ូយ៉ាងស្វិតស្វាញរបស់សម្ព័ន្ធសមណនិស្សិត ចំពោះសង្គមខ្មែរក្រោម នាងថ្លែងថា “ដោយសារនិរន្តភាពរបស់សម្ព័ន្ធសមណនិស្សិតនេះហើយ ទើបនិស្សិតយើងខ្ញុំខ្លះ ដែលខ្វះលទ្ធភាពក្នុងការបន្តការសិក្សានៅមហាវិទ្យាល័យ ក៏ត្រូវបានសប្បុរសជននានានៅបរទេស មានសហព័ន្ធខ្មែរកម្ពុជាក្រោម ជួយផ្គត់ផ្គង់អាហារូបករណ៍ឲ្យបានរៀនបន្តរហូតដល់ចប់ចុងចប់ដើម ។ ដោយគុណបំណាច់របស់បណ្ដាអង្គភាព និងអស់លោកនេះ យើងខ្ញុំសូមប្ដេជ្ញាចិត្តថា នឹងខិតខំកសាងខ្លួនឲ្យសមនឹងទំពាំងស្នងឫស្សី” ។

ក្នុងកិច្ចការសំណេះសំណាលប្ដូរបទពិសោធន៍គ្នា នាឱកាសជួបជុំគ្នានេះ ព្រះភិក្ខុសមណនិស្សិត សាសន៍ ចំរើន បានផ្ដល់អនុសាសន៍ បទពិសោធន៍ដ៏ល្អមួយចំនួន ដែលព្រះអង្គបានឃើញ បានជួបប្រទះ និងបានអនុវត្តពីបណ្ដាប្រទេសជឿនលឿនខ្លះ ចែកជូនដល់សមណនិស្សិត និស្សិតឲ្យបានដឹងគ្រប់អង្គ គ្រប់គ្នា ។ ព្រះអង្គក៏បានសំដែងនូវការតូចចិត្តដូច្នេះ “ជាការពិត គឺយើងសោកស្ដាយណាស់ចំពោះការដែលបារាំងកាត់ទឹកដីយើងឲ្យទៅយួននៅថ្ងៃទី ០៤ មិថុនា ១៩៤៩ នោះ តែយើងខិតខំទាំងអស់គ្នាទៅ គង់តែបានមកយើងវិញទេ ព្រោះបារាំងធ្វើនេះ ខុសនឹងច្បាប់អង្គការសហប្រជាជាតិទាំងស្រុង ។

រីឯព្រះតេជគុណ យឿង សិន ដែលជាប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម និងក្នុងនាមជាអធិបតីនៃអង្គពិធី ព្រះអង្គមានព្រះទ័យត្រេកអរ ចំពោះទង្វើខ្នះខ្នែងតស៊ូរបស់សមណនិស្សិត និស្សិតគ្រប់រូប និងចំពោះវត្តមានរបស់ភ្ញៀវចូលរួមទាំងអស់ ព្រមទាំងរំឭកបន្ថែមដល់សមណនិស្សិត និស្សិតឲ្យខិតខំរៀនសូត្រទ្វេឡើង ដើម្បីជួយសង្គ្រោះជាតិមាតុភូមិ ជាតិមាតុភូមិយើងសង្ឃឹមលើអ្នកទាំងអស់គ្នានេះហើយ ដែលជាទំពាំងស្នងឫស្សីដ៏រឹងមាំបំផុត ។

ក្នុងអង្គពិធីនេះ ក៏មានយុវជននិស្សិតខ្មែរក្រោមពីររូបនៅទីក្រុងព្រៃនគរ បានទៅចូលរួមហើយពួកគេបានឲ្យយើងដឹងថា “ពួកគេមានអារម្មណ៍រំភើបរីករាយណាស់ ហើយពួកគេបានត្អូញត្អែរប្រាប់យើងថា ពួកគេនៅក្រោមរបបអាណានិគមយួន យួនមិនអនុញ្ញាតឲ្យរៀបចំកម្មវិធី ដោយសេរីដូច្នេះទេ ។ រាល់ការរៀបចំកម្មវិធីអ្វីមួយរបស់ពួកគេម្ដង ៗ ត្រូវបានសមត្ថកិច្ចយួនឃ្លាំមើល និងបង្គាប់បញ្ជាថា ត្រូវធ្វើអីចេះធ្វើអីចុះ ពួកគេមិនអាចធ្វើអ្វីមួយ ឬនិយាយនូវអ្វីតាមការចូលចិត្ត ឬតាមបំណងប្រាថ្នារបស់ពួកគេនោះបានទេ ។

កម្មវិធីជួបជុំនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ទទួលអំណរឆ្នាំថ្មី ឆ្នាំរកា សប្ដស័ក បានចប់សព្វគ្រប់នៅវេលាម៉ោង ១៣:០០ ថ្ងៃដដែល បន្ទាប់ពីមានពិធីរាប់បាត្រព្រះសង្ឃជាង ២៥០ អង្គ និងការលេងល្បែងប្រជាប្រិយផ្សេង ៗ ព្រមទាំងរាំកំសាន្តផង ពីសំណាក់យុវនិស្សិតយើងពោរពេញដោយភាពអ៊ូរអរ និងរីករាយក្រៃលែង ៕

*វិទ្យុសំឡេងកម្ពុជាក្រោម* (VOKK)

# ទាពក្រីក្រកំពុងគំរាមកំហែងប្រជារាស្ត្រខ្មែរភូមិស្លាប៉ាំង

*ភូមិស្លាប៉ាំងស្ថិត ក្នុងឃុំរំដួល ( Dong chau) ស្រុកថ្កូវ ( Tra Cu) ខេត្តព្រះត្រពាំង ។*

*ភូមិស្លាប៉ាំង មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣១៥ គ្រួសារ ដែលមានសមាជិកមធ្យមក្នុងមួយគ្រួសារចំនួន ៥ នាក់ ។ ប្រជារាស្ត្រខ្មែរក្នុងភូមិនេះជំពាក់បំណុលរដ្ឋការសរុប ៤០០០.០០០.០០០ (បួនពាន់លានដុង) និងភាគច្រើនកំពុងបោះបង់ ផ្ទះសំបែង ស្រែចំការ ទៅធ្វើជាកម្មករនៅទីក្រុងព្រៃនគរ និងទីក្រុងភ្នំពេញ ។*

ភូមិស្លាប៉ាំង មានចម្ងាយប្រមាណ ៩៥ Km ពីទិសខាងត្បូងនៃទីរួមខេត្តព្រះត្រពាំង និងមានប្រជារាស្ត្រខ្មែររស់នៅយ៉ាងច្រើនកុះករ ដូចភូមិខ្មែរដទៃទៀត នៃខេត្តព្រះត្រពាំងអញ្ចឹងដែរ ។

ក្នុងទសវត្សរ៍ទី ៤០ សម័យយៀកមិញលុកលុយ និងក្នុងទសវត្សរ៍ទី ៥០ សម័យជម្លោះ ង៉ោ ឌិនយីម និង ហូជីមិញ ព្រមទាំងក្នុងទសវត្សរ៍ទី ៧០ សម័យជម្លោះពួកវៀតកុង និង ធីវគី ភូមិស្លាប៉ាំងក៏មិនខុសអំពីភូមិខ្មែរផ្សេង ៗ ទៀតទេ គឺត្រូវរងការបំផ្លាញពីពួកយួនយ៉ាងដំណំ ។

តាំងពីដើមរៀងមក មុខរបរជាចម្បងរបស់ប្រជារាស្ត្រខ្មែរភូមិស្លាប៉ាំង គឺធ្វើស្រែចំការ ឯរបរនេសាទ ក៏មានតិចតួចផងដែរ ។ ប្រជារាស្ត្រខ្មែរភូមិស្លាប៉ាំងក្នុងមួយគ្រួសារៗ មានដីស្រែរាប់សិបហិច-តា ជីវភាព សម្បូរហូរហៀរ ប្រាក់មិនខ្វះចាយ បាយមិនខ្វះហូប លំនៅស្ថានធំ ៗ ដំបូលក្បឿង ជញ្ជាំងក្តារ សរសរធ្នឹក តែចាប់តាំងពីក្រោយឆ្នាំ ១៩៧៥ មក ជីវភាពរស់នៅរបស់ប្រជារាស្ត្រខ្មែរចេះតែថយចុះជាលំដាប់ ។ តាមប្រសាសន៍របស់លោក អ៊ំ ថាច់ វង្ស បានឲ្យដឹងថា "ការថយចុះនៃកម្រិតជីវភាពរបស់ប្រជារាស្ត្រខ្មែរនេះ ដោយអាស្រ័យដីស្រែចម្ការរបស់ពួកគាត់ ត្រូវបានអាជ្ញាធរកុម្មុយនិស្តយួនដកហូតយក និងបង្ខំឲ្យប្រកបជីវភាពក្នុងរបបសមូហភាព" ។

ប្រជារាស្ត្រខ្មែរក្នុងភូមិស្លាប៉ាំង បានឲ្យយើងដឹងបន្ថែមថា "ជីវភាពរបស់ពួកគាត់ កាន់តែធ្លាក់ចុះ បន្ទាប់ពីឆ្នាំ ១៩៩០ មក គឺក្រោយពីពួកគាត់មួយចំនួន ប្រកាន់យកមុខរបរចិញ្ចឹមបង្គាជាធំ ។

ទាក់ទិននឹងបញ្ហាប្រកបមុខរបរចិញ្ចឹមបង្គា បណ្តាលឲ្យជីវ-ភាពរបស់ប្រជារាស្ត្រខ្មែរស្រុកស្លាប៉ាំងធ្លាក់ចុះនេះ បងប្រុស សឺន គិន បានឲ្យយើងដឹងថា "ការខូចខាតក្នុងការចិញ្ចឹមបង្គារបស់គាត់ មកពីគាត់ខ្វះទុន និងម្យ៉ាងទៀត តម្លៃបង្គាមិននឹងនរសោះ រដូវខ្លះក៏បានថ្លៃ ឯរដូវខ្លះក៏ស្រាប់តែចុះថោក ។ ចំណែកបងប្រុស ថាច់ កុសល បានអួតប្រាប់យើងដូច្នេះ "កាលចាប់ផ្តើមចិញ្ចឹមបង្គាដើមដំបូង បង្គាររបស់គាត់ចេះតែខូចមិនឈប់ ដោយសារតែគាត់ពុំទាន់មានបទពិសោធន៍នឹងមុខរបរនេះ ពេលនេះមុខរបរគាត់បាននឹងនរ និងបានទទួលកម្រៃគួរសមដែរ ។ គាត់បានឲ្យដឹងបន្ថែមថា ការដែលគាត់បានទទួលផលកម្រៃពីការចិញ្ចឹមបង្គានេះ ក៏ដោយអាស្រ័យថា ពេលនេះគាត់មានបទពិសោធន៍ហើយ គួបផ្សំនឹងមានបងប្អូននៅក្រៅប្រទេសជួយទុនជាប្រចាំផង គាត់ពុំបានខ្ចីបុលនរណាទេ ពេលដែលបង្គារបស់គាត់រងការខូចម្តងម្កាលនោះ" ។

ឯអ៊ំស្រី ថាច់ ធីកង ស្ថិតនៅភូមិស្លាប៉ាំង ដែលផ្ទះរបស់គាត់មើលទៅដំបូលស័ង្កសីទើបតែប្រក់ថ្មី ៗ អ៊ំបានឲ្យដឹងថា ផ្ទះនេះរដ្ឋគេជួយសង់ឲ្យ ហើយគេសង់ឲ្យនេះ មានតែសរសរ និងដំបូល ឯជញ្ជាំង ទ្វារ បង្អួច ឬការចាក់បេតុងធាផ្ទះគ្មាននោះទេ តែរដ្ឋគេប្រាប់ថាផ្ទះនេះគេធ្វើអស់ ៥ លានដុង ។ តាមការប៉ាន់ស្មានរបស់អ្នកស្រុកអ្នកភូមិនៅទីនោះ បានដឹងថា ចំនួនទឹកប្រាក់ ៥ លានដុងបើប្រគល់ឲ្យប្រជារាស្ត្រសាងសង់ខ្លួនឯង បើធ្វើផ្ទះទាបផ្ទាល់ដីបែបនេះ ពួកគាត់អាចធ្វើបានសមរម្យជាងនេះ ដោយមានទាំងបង្អួច ទ្វារ ជញ្ជាំង និងក្រាលបេតុងធាផ្ទះទៀតផង ។

នៅឯទីក្រុងព្រៃនគរនេះវិញ ប្អូនប្រុសឈ្មោះ សឺន មិញ អាយុ ២១ ឆ្នាំ ជាកម្មករផលិតគ្រឿងជ័រ និងប្អូនស្រីឈ្មោះ គីម ធីឡាង អាយុ ១៩ ឆ្នាំ ជាអ្នកបម្រើតាមផ្ទះ ប្អូនទាំងពីរ បានឲ្យដឹងថា "ខ្មែរយើងមកធ្វើកម្មករនៅព្រៃនគរនេះច្រើនណាស់ រាប់ពាន់នាក់ឯណោះ ដោយឡែកប្អូនទាំងពីរ មានស្រុកកំណើតនៅភូមិស្លាប៉ាំង ឃុំរំដួល ។ អ្នកទាំងពីរ បានចាកចោលផ្ទះសំបែង ឆ្ងាយពីឪពុកម្តាយ បងប្អូន ចោលការសិក្សា មកធ្វើជាកម្មករនេះ ក៏ព្រោះថា ដីស្រែចម្ការរបស់ឪពុកម្តាយប្អូន (សឺន មិញ) ដែលក្រោយពីឆ្នាំ ១៩៧៥ នៅសល់បន្តិចបន្តួចនោះ ពេលនេះត្រូវបានម្ចាស់បំណុលរឹបអូសយកអស់ទៅហើយ ដោយសារតែការខ្ចីទុនគេមកចិញ្ចឹមបង្គា ។

បែរមកបងស្រី ថាច់ ធីសុខុម រស់នៅភូមិស្លាប៉ាំងដែរ ដែលទើបតែត្រឡប់មកពីក្រុងភ្នំពេញ បានរៀបរាប់ពីដំណើររឿងរបស់គាត់ឲ្យយើងដឹងថា "គ្រួសារគាត់មានកូនទាំងអស់ ៤ នាក់ គាត់និងកូនស្រីច្បងអាយុ ១៨ ឆ្នាំ ព្រមទាំងកូនប្រុសអាយុ ១៤ ឆ្នាំម្នាក់ បានចុះឡើងទីក្រុងភ្នំពេញជាងមួយឆ្នាំមកហើយ បងស្រី និងកូនទាំងពីរទៅទីក្រុងភ្នំពេញប្រកបមុខរបររុញរទេះលក់ទឹកសណ្តែក និងលក់នំប៉ុងសាច់ ។ មុខរបរនេះ រកកម្រៃដោយខ្លួនឯង ពុំបានធ្វើជាកម្មករគេឡើយ ។ បងបញ្ជាក់ថា "ឯប្តីរបស់គាត់ និងកូនតូច ៗ ២ នាក់ នៅផ្ទះមើលថែទាំផ្ទះសម្បែង និងដាំដុះបន្តិចបន្តួច ឯបងស្រីទៅភ្នំពេញខំរកបន្សែបន្សំលុយកាក់ ដើម្បីយកមកលោះស្រែភ្លឺឡើងវិញ ។ ព្រោះប៉ុន្មានឆ្នាំមកនេះ ដោយការមិនប៉ិនប៉ៅក្នុងការថែរក្សាបង្គា ធ្វើឲ្យការចិញ្ចឹមបង្គារបស់គាត់ខូចខាតជានិច្ច ។

ចំពោះស្ថានភាពគ្រួសារប្រជារាស្ត្រនៅភូមិស្លាប៉ាំង លោកប្រធានភូមិរងភូមិនេះ បានឲ្យដឹងថា ៖

-"ភូមិស្លាប៉ាំងមានប្រជារាស្ត្រសរុប ៣២៥ គ្រួសារ ក្នុងនេះ

ខ្មែរ ៣១៥ គ្រួសារ យួន ១០ គ្រួសារ ។ គិតជាធម្យមក្នុង ១ គ្រួសារមានគ្នា ៥ នាក់ ។

–ចំនួនលុយ ដែលប្រជារាស្ត្រខ្មែរជំពាក់អាជ្ញាធរយួន សរុបបួនពាន់លានដុង ។

–ជំនួយឥតសំណងរបស់អង្គការ CAMA (ខេមា) ផ្តល់ដល់ប្រជារាស្ត្រខ្មែរក្នុងភូមិនេះចំនួន ៦០ គ្រួសារ ។ ក្នុង ១ គ្រួសារ ១០ លានដុង សម្រាប់ជាទុនសង់ផ្ទះនៅវាលទំនាបទឹកលិច (វាលស្រែចិញ្ចឹមបង្គា) ឥឡូវអ្នកខ្លះបោះបង់ចោលផ្ទះអស់ហើយ ព្រោះគ្មានលទ្ធភាពលើកផាផ្ទះឲ្យផុតពីទឹកជោររាល់ថ្ងៃនោះបានទេ ។

ក្នុងភូមិស្លាប៉ាងទាំងមូល រដ្ឋការយួនជំនួយសង់ផ្ទះឲ្យដោយខ្វះមុខខ្វះក្រោយ បានចំនួន ៩ ខ្នង គិតជាទឹកប្រាក់ក្នុង ១ ខ្នង ប្រាំលានដុង ។

ចំនួនយុវជន យុវនារីខ្មែរក្រោម ៩៥% កំពុងចាកចោលភូមិស្រុកទៅធ្វើជាកម្មករនៅទីប្រជុំជនផ្សេង ៗ ទាំងក្នុងស្រុក និងក្រៅស្រុក ។

លោកប្រធានភូមិរងស្លាប៉ាង បានបញ្ជាក់យ៉ាងធ្ងន់បន្ថែមថា "ខ្មែរក្រោមជាកូនបំណុលរដ្ឋយួន និងមេឈ្មួញយួនមួយចំនួន កំពុងប្រឈមមុខនឹងការបាត់បង់ ដីស្រែ ចម្ការ ព្រោះគ្មានលុយសងមេបំណុល ៕

VOKK

# អតីតព្រះរាជាឈាតត្រដាង
# កម្ពុជាក្រោម-ព្រៃនគរ-កោះត្រល់
# បារាំងជាអ្នកទទួលខុសត្រូវ

*ក្នុងអត្ថបទមួយរបស់សម្តេចឪ ព្រះមហាវីរក្សត្រ ចុះថ្ងៃទី ០៥ ឧសភា ឆ្នាំ ២០០៥ ផ្សាយតាមវ៉ែបសាយរបស់ព្រះអង្គជាភាសាបារាំង ដែលកោះសន្តិភាពបានបកប្រែក្រៅផ្លូវការ ទាក់ទិនដល់បញ្ហានៃការបាត់បង់ទឹក-ដីកម្ពុជាក្រោម ។ ក្នុងអត្ថបទនោះ សម្តេចឪទ្រង់មានព្រះរាជតំរិះថា មានឥស្សរជនខ្មែរយើងខ្វះ បានចោទប្រកាន់ ព្រះមហាក្សត្រយើងក្រោយសម័យអង្គរមួយចំនួនថាជាអ្នកទទួលខុសត្រូវដោយផ្ទាល់ ចំពោះការបាត់បង់ទឹកដីកម្ពុជា ទៅបណ្តាប្រទេសជិតខាង។*

*ចម្លើយដ៏ខ្លីរបស់ខ្ញុំ ចំពោះការចោទប្រកាន់ទាំងនេះមានដូចតទៅ ៖*

*១- បន្ទាប់ពីសម័យអង្គរមក មានការបាត់បង់ទឹក-ដីខ្មែរ នៅក្រោមរាជ្យរបស់ព្រះមហាក្សត្រខ្មែរអង្គនេះ ឬអង្គនោះ ។ ប៉ុន្តែប្រការនោះកើតមាន ដោយសារតែការហត់នឿយបំផុតរបស់បណ្តាចក្រពត្តិនិយមបារាំង ឬ ពួកស្តេចណាប៉ូឡេអុងដូច្នេះដែរ ។ អាណាចក្ររបស់ណាប៉ូ-ឡេអុងទី ១ ត្រូវបានបញ្ចប់គួរឲ្យសោកសៅ គឺប្រទេសបារាំង បាននៅសល់យ៉ាងតូចជាងកាលពីស្ថិតនៅក្រោមការដឹកនាំរបស់បូណាប៉ាត និងក្រោមការគ្រប់គ្រងរបស់ណាប៉ូឡេអុងទី ១ ។*

*២-ទាក់ទិនដល់ដែនដីកម្ពុជាក្រោម និង ព្រៃនគរ កងទ័ពរបស់ព្រះករុណាព្រះអង្គឌួង បន្ទាប់មករបស់ព្រះ-ករុណា ព្រះនរោត្តម បានប្រយុទ្ធរហូតដល់ទីបញ្ចប់ប្រឆាំងនឹងកងកម្លាំងរបស់ពួកអាណ្ណាម ឈ្មានពាន និងអាណានិគម ។ ការតស៊ូនោះបន្តរហូតដល់ពួកអា-ណានិគមបារាំងដណ្តើមត្រួតត្រាឥណ្ឌូចិន ហើយគឺពួក-អាណានិគមនិយមបារាំងនេះហើយ ជាអ្នកទទួលខុស-ត្រូវតែមួយគត់ចំពោះការ*

*ប្រគល់ឲ្យវៀតណាមនូវដែនដីកម្ពុជាក្រោម ទឹកដីព្រៃនគរ និង កោះត្រល់របស់យើង ៕*

*អត្ថបទដកស្រង់ចេញពីសារព័ត៌មានកោះសន្តិភាព*

# រឿងកំពប់តែអុង

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃីន សុខ



ឃួនយកក្បាលខ្មែរធ្វើជាមុំចង្ក្រានកល់ដាំតែអុង

(**តពីលេខមុន**)

២៨៨-បទព្រហ្មគិតកាប់ ចរចាចាប់ចងពាពេជ្ឈ
ពីក្រោយនោះបន្តិច ទើបអង្គស្តេចឧទៃរាជា ។

២៨៩-ស្តេចគង់សុកសប្បាយ
ខ្សែមលោះលាយអង្គឯអាច
ស្តេចឃ្យទូនយោមរាជ
ជាចៅហ្វាកាលនោះមិញ ។

២៩០-ឡើងស័កសឹងជាធំ
ផ្ងាចាមជុំចូលពាសពេញ
ចៅហ្វារទូននោះមិញ
តាំងចិញ្ចឹមជាងទាំងឡាយ ។

២៩១-សុទ្ធសឹងតែចាមផ្ងា
ឲ្យធ្វើជាងលុះសព្វសាយ គ្រប់ខែត្តផងទាំងឡាយ
សឹងជានាយជាធំធួន ។

២៩២-កាលនោះអុងតាគុង ខ្ចីយមានបុណ្យស័ក្តសមសួន
គាត់ប្រើបំរើឃួន មកបង្គាប់ម្ចាស់យើងអោយ ។

២៩៣-ឲ្យគិតកែនយកមនុស្ស ខ្មែរឲ្យអស់ខែត្តទាំងឡាយ
សំនួនពលពីអោយ អស់គ្រុបនាយ៥ម៉ឺនគត់ ។

២៩៤-ហើយឲ្យមានមន្ត្រី ត្រួតបញ្ជីជាកំណាដ្ឋ
៥ម៉ឺនមែនប្រាកដ ទើបអុងឲ្យលេងទោសនោះ ។

២៩៥-បទអុងចង់ជីកដី ព្រៃកជាថ្មីកាត់ទំលុះ
ពីពាមមាត់ជ្រូកនោះ កាត់ទម្លុះតម្រង់ទៅ ។

២៩៦-ត្រូវពាមព្រះសោទ័ត មាត់ស្រមុទ្រនោះឯងកូវ
ហេតុនោះអុងឲ្យត្រូវ កេនមនុស្សទៅជួយរាជកា ។

២៩៧-ព្រះបាទឧទៃរាជ ភិតខ្លបខ្លាចឱអុងណាស់ណា
ចាត់ចែងចែកយោធា ចេញដោយនាខែត្តទាំងឡាយ ។

២៩៨-ឯព្រះរាជអាញា ចេញត្រួតត្រាខេត្តបារាយណ៍
កាលនោះនាមចៅហ្វាយ សែង្ហាងហ្វារក្សាស្រុក ។

២៩៩-ឯដើមដំណើរនោះ តាមហៅឈ្មោះឧកញ្ញាម៉ុក
ធ្វើជារក្សាស្រុក ស្នងនាមនោះឈ្មោះហៅកែ ។

៣០០-គិតកែនមនុស្សទាំងឡាយ ខែត្តបារាយមកបង្ហែរ
ចូលជុំផ្ទះស្នងកែ គិតថ្មូនថែរអស់គ្រប់គ្រាន់ ។

៣០១-សំនួនតាមបញ្ជី ចែកពិតពីក្បាលខែត្តខាន់
ទើបចែកមេគិតកាន់ តាមសំនួនកូនក្រុំមេ ។

៣០២-ឯអង្គឧញ្ញាម៉ុក ផ្តាំដាក់ទុកនិងស្នងកែ
ឲ្យមើលឲ្យធួនថែរ ធ្វើជាមេធំសម្រេច ។

៣០៣-ផ្តែផ្តាំអញ់ហ្មត់ហ្មង រៀបផ្គូរផ្គងចេញចរត្រាច់
នាំមនុស្សទៅថ្វាយស្តេច ដូចតំរាស់ព្រះអាជ្ញា ។

៣០៤-ព្រះបាទឧទៃរាជា រាស្ត្រខ្លបខ្លាចឥតឧបមា
កែនបានមកត្រៀបត្រា គ្រប់សំនួនបញ្ចូនអស់ ។

៣០៥-ហើយត្រាស់ឲ្យឧកញ្ញា យោមរាជជាងដើមឈ្មោះ
រស្សនាំមនុស្សទៅទាំងអស់ ជាមេកងជីកព្រៃកនោះ ។

៣០៦-យោមរាជរស្សជាធំ មេកងជុំជិតពិគ្រោះ
និងជីកព្រៃកនោះទំលុះ តាមអុងនោះវាសចែកចាយ ។

៣០៧-រីឯអង្គស្នងកែ ដែលជាមេខែត្តបារាយ
យោមរាជរស្សជានាយ ធំសំរេចដាច់រាជ្ការ ។

៣០៨-ស្នងកែគាត់មិនខ្លាច បុណ្យយោមរាជរស់ធំជា
សំរេចដាច់រាជការ បង្គាប់ការពុំកោតខ្លាច ។
៣០៩-គាត់អាងបុណ្យក្សត្រា ទ្រង់កូរណាអង្គឯងអាជ្ញ
ហេតុនេះគាត់ពុំខ្លាច ពុំកោតក្រែងយោមរាជសោះ ។
៣១០-ឯឧកញ្ញាយោមរាជ យល់ពុំខ្លាចខ្លួនដូច្នេះ
សំគាល់ទោសទាំងនោះ ចំណាំចាំទុកទៅ ។
៣១១-លុះចាប់ជីកព្រែក អុងឲ្យចែកនាយមួយកូវ
កូន១០ដើរមួយផ្លូវ សែងដីទៅទាក់ទាល់ទើស ។
៣១២-ប្រាំបីនាក់ស្នែងបួន គិតសំនួនច្រនីកពីរ
ឲ្យចាំជីកនៅទី ក្នុងពោះព្រែកចែកនោះហោង ។
៣១៣-នាយមួយមានយួនបី ចាំក្បាលទីចុងទីផង
កណ្តាលយួនមួយផង ចាំវាយខ្នងឲ្យរត់ឆាប់ ។
៣១៤-ដើមទីប្រើកើបដី មិនឃ្នាតខ្មីខំប្រញាប់
អង្គុយកើបវាយខ្វាប់ៗ ឲ្យឈរកាប់កកាយវិញ ។
៣១៥-កើបបានហើយឲ្យឯង លើកលីសែងរត់ឃ្នាតខ្មាញ់
ដល់ចុងទីនោះមិញ ឲ្យរលាក់ចាក់ប្រញាយ ។
៣១៦-បើធ្វើឲ្យយឺតយូរ មិនបន្ទូរឲ្យធ្លាក់ឆាប់
ចុងទីវាវាយខ្វាប់ ឲ្យប្រញាប់វិលវិញ ។
៣១៧-តែងសែងរត់ទៅមក មិនឲ្យជ្រកដល់តិចសោះ
រីមនុស្សអស់ទាំងនោះ ស្ទើរនិងសោះស្លាប់ទីទៃ ។
៣១៨-ដរាបដល់ព្រលប់ ចាស់ដេកលុកយប់នោះនៃ
ទើបអុងឯងឲ្យវាយ ត្រដោកឈប់យប់ដេកនៅ ។
៣១៩-លុះមាន់រងាវខ្វា វាយឲ្យចុះលើកទៀតទៅ
សព្វថ្ងៃដូច្នេះកូវ រាស្ត្រនឹងនៅទ្រាំពុំបាន ។
៣២០-អង្គរអុងឲ្យដាក់ ជាដំណាក់រាសគ្រប់ប្រាណ
អណ្តែតលើទឹកបាន ឃ្លានប៉ុន្មានលេបឆង្អោរ ។
៣២១-អង្គរគេដាក់ឃ្លាង គេបំព្រាងទឹកកំបោរ
ខំលេបទៅចង្អោរ ហើយហើមពោះចុងផ្ទៃផង ។
៣២២-ឯទឹកសោតសឹងល្អក អាសោចល្មកក្រែកន្លង
ដោយសារមនុស្សច្រើនផង នឹងរករុងកលគិតគ្មាន ។
៣២៣-ឯមនុស្សផងគ្រប់គ្នា ខំធ្វើការហើយស្រេកឃ្លាន
និងផឹកទឹកមិនបាន អស់អង្គប្រាណណាស់ទីទៃ ។
៣២៤-ដល់ដាលទៅជាឈឺ មានជម្ងឺលុះក្សិណក្ស័យ
លំបាក់ពន់ពេកក្រៃ ល្ហិតល្ហើយល្វែអស់អាត្មា ។
៣២៥-អស់រាស្ត្រផងទាំងឡាយ ពុំសប្បាយបទរាជការ
នឿយហត់អត់គ្រប់គ្នា នឹងភោក្តាពុំពេញពោះ ។
៣២៦-ពលខ្មែរគ្រប់សំនួន ដោយពលយួនធ្វើការនោះ
ដោយគិតគូរពិគ្រោះ ទាំងនោះសែនមួយប្លាយ ។
៣២៧-ចុះម្តងដាក់ដោយទី គ្រប់បញ្ជីពលទាំងឡាយ
សំនួនឯចម្ងាយ ដើរគិតផ្លូវត្រូវយប់ ។
៣២៨-ទើបផុតអស់ពួកពល ធ្វើការយល់យួនប្រសព្វ
ពួកខ្មែរយើងទាំងគ្រប់ ពុំប្រសព្វការទាន់យួន ។
៣២៩-គេចុះទីណាម្តង រួចហ្មត់ហ្មងគ្រប់សំនួន
គេចាំឯងគ្រប់ខ្លួន បានសំនួននឹងបើកទឹក ។
៣៣០-អុងឲ្យគេប្រាមប្រាប់ ធ្វើឲ្យឆាប់រួចពីព្រឹក
ស្រេចហើយគេបើកទឹក ហូរគគិកពេញព្រោះព្រែក ។
៣៣១-អ្នកណាយឺតដៃជើង ពិតពុំឡើងកាលគេស្រែក
លិចលុងក្នុងពោះព្រែក ព្រោះហូរប្លែកណាស់នៃ ។
៣៣២-ហូរចូលបាតតើក ខ្លាំងពន្លឹកពន់ពេកក្រៃ
លិចលុងក្នុងនោះក្ស័យ សត្វដោយន័យគង្គារហោង ។
៣៣៣-ទទឹងព្រែក១០ព្យាម ជំរៅទាម៥ព្យាមស្មោះ
លិចលង់ក្នុងព្រែកនោះ សត្វសានចុះដោយទឹកទៅ ។
៣៣៤-ធ្វើការជីកព្រែកនោះ ហៀបនឹងបានស្រមុតក្រៅ
មនុស្សនឿយណាស់និងនៅ ពិតពុំបានបទស្លាប់ណាស់ ។
៣៣៥-វានឿយហើយស្គមស្គាំង អន់កំឡាំងពុំរហ័ស
យួនយល់យឺតវាស់ណាស់ ថាខ្មែរចាស់ពុទ្ធវាច្រើន ។
៣៣៦-វាយដំកំរើកខ្លួន នោះឯងយួនរឹតរឹងខឹង
ថាខ្មែរមិនខំប្រឹង វាបានដឹងវាយពុំលែង ។
៣៣៧-បើវាយពុំកក្រើក ពុំរំពើកខ្លួននោះឯង
ទើបបានយួនវាលែង ល្មមតែឯងស្លាប់ប្រាកដ ។
៣៣៨-ខ្មែរយល់យួនដូច្នេះ គិតគ្នាស្រុះស្រាប់សន្មត់
យល់យប់ស្ងាត់ប្រាកដ គិតគ្នារត់ចេញប្រញាយ ។
៣៣៩-រត់ចរចាកចេញទៅ ដោយនៅស្រុកជិតឆ្ងាយ
គ្រប់ខេត្តផងទាំងឡាយ បែកខ្ចាត់ខ្ចាយគ្នាទីទៃ ។
៣៤០-ខ្លះរត់រួចដល់ទៅ ទីលំនៅឯងនោះន័យ
នាំកូនចៅចូលព្រៃ ពឹងប្រាស្រ័យលាក់អង្គប្រាណ ។
៣៤១-ខ្លះមានទន្លេខាន់ ទៅពុំទាន់ដល់ទីស្ថាន
លួចទូកឆ្លងពុំបាន នៅយប់ខានពួកទីព្រៃ ។
៣៤២-ព្រោះខ្លាចគយល្បាតគេ គ្រប់ទន្លេព្រែកធ្វេកន្សៃ
រង្គាត់តែសព្វថ្ងៃ បើបានដៃចាប់ជូនអុង ។

៣៤៣-អស់រាស្ត្ររត់ទាំងឡាយ និងនិយាយឲ្យចប់ចុង
វាច្រើនណាស់បង្អង់ និយាយចុងឯក្រោយវិញ ។
៣៤៤-បទកាលក្រោយរាស្ត្ររត់ អស់ប្រាកដដនោះឯង-
មិញ យោមរាជរស់គេចេញ ទៅប្តឹងអុងឯងសព្វសាយ ។
៣៤៥-ថារាស្ត្ររត់ទាំងនេះ ហេតុជំនេះស្នងបារាយ
ស្នងកៃជានាយ នាំនិយាយឲ្យរាស្ត្ររត់ ។
៣៤៦-ទើបរាស្ត្រខែត្តឯទៀត វាឈ្លបឈ្លៀតដឹងប្រាកដ
ថាស្នងកៃគេមុត ឲ្យវារត់ទៅកុំខ្លាច ។
៣៤៧-ឯអុងយួនបានស្តាប់ អស់សារសព្វពាក្យយោមរាជ
ថាស្នងកៃគិតកាច អាចបញ្ឆោះរាស្ត្រទាំងឡាយ ។
៣៤៨-អុងយួនពុំពិគ្រោះ ឲ្យជំពោះពាក្យនិយាយ
ចូលចិត្តដើរសព្វសាយគិតចាត់ចាយចេញចោមចាប់ ។
៣៤៩-រីឯស្នងកៃនោះ ពុំដឹងគ្រោះក្រនិងស្លាប់
លុះតែគេចោមចាប់ ចង់បានខ្ជាប់ភ្ជាក់អាត្មា ។
៣៥០-ពុំដឹងទោសកលអ្វី និងស្រដីដោះទោស្សា
គេចាប់ចងអាត្មា និងទៀបទៅសម្លាប់ ។
៣៥១-ដោតក្បាលជាបម្រាម កុំឲ្យតាមយកតម្រាប់
ស្រេចហើយគេយកទ្រព្យ គ្រឿងប្រដាប់ឥតសង្ស៊ែ ។
៣៥២-ចិញ្ចៀនត្បូងមាសប្រាក់ ដែលគាត់ពាក់គ្រប់-
ម្រាមដៃ គេបូតយកទីទៃ អង្គឯងក្ស័យសូន្យអាសារ ។
៣៥៣-ឱះឱរូបសព្វសត្វ គួរគន់គិតរូបរាល់គ្នា
ទ្រព្យធនបុនស័ក្តា សឹងឥតការដូច្នេះឯង ។
៣៥៤-ឯរូបចោលនៅដី ជាចំណីក្អែកត្មាតខ្លែង
វាចិកវាជញ្ជែង ជាចំណីនៅក្នុងព្រៃ ។
៣៥៥-កាលអុងឲ្យចោមចាប់ ចងស្នងខ្ជាប់បាននោះនៃ
ជ្រាបដល់ក្សត្រជៀសជ័យ ឧទៃរាជរិះគិតឆាប់ ។
៣៥៦-ស្តេចត្រាស់ឲ្យអាមាត្រ ចរខ្មីឃ្មាតជាប្រញាប់
ទៅសុំកុំឲ្យកាប់ និងឲ្យទ្រព្យជារង្វាន់ ។
៣៥៧-អាមាត្រចរចេញទៅ តាមដោយនៅក្សត្រសោភ័ន
អាមាត្រទៅមិនទាន់ គេក្សបកាប់គិតមុនស្រេច ។
៣៥៨-អាមាត្រដឹងដើមក្តី វិលវឹងខ្មីចេញចរត្រាច់
មកទូលទាល់អង្គស្តេច ដោយដំណើរនោះសព្វសាយ ។
៣៥៩-ស្តេចស្តាប់អាមាត្រទូល ក្សត្រឥសូរសោយសោក-
ស្តាយ ស្នងនោះព្រោះប្រាជ្ញប្រាយ
គិតការថ្វាយពិតពុំភ្លង ។

៣៦០-ប្រាជ្ញាគាត់វៀងវៃ អាធ្យាស្រៃកិច្ចការចង ពាក្យ-
ពេជល្បាចល្បិកល្បង ទាក់ណែងណងរៀងរាបទាប ។
៣៦១-គាត់ចេះទាំងឆ្លាក់គូរ ក្បោះក្បាច់ក្បូរផងដរាប
សំដីពិរោះរាប ត្រូវព្រះទ័យមហាក្សត្រា ។
៣៦២-ហេតុនោះមហាក្សត្រថ្លៃ សព្វព្រះទ័យតែងករុណា
ស្តេចសែនសោយសោកា រកអ្នកណាដូចគាត់គ្មាន ។
៣៦៣-ស្នងកៃគាត់ក្សិណក្ស័យ សូន្យនៅព្រៃព្រឹក្សស្មសាន្ត
បងប្អូនសាច់សន្តាន វិលវឹងថ្កានភូមិបារាយណ៍ ។
៣៦៤-គេចូលទៅប្តឹងប្រាប់ អស់សាសព្វសូន្យនៅនាយ
ឲ្យកូនប្រពន្ធម្តាយ ញាតិទាំងឡាយដឹងដើមដាក់ ។
៣៦៥-គេចាប់ត្បិតស្នងកៃ យួនឯងឯគិតសម្លាប់
ហ្លួងប្រើបំរើឆាប់ ឲ្យទៅសុំពុំទាន់ឡើយ ។
៣៦៦-នាងយូបានស្តែងស្តាប់ ពាក្យគេប្រាប់ដូច្នោះហើយ
សឹងសោយសោកាជាត្រើយ ពិតពុំស្បើយពីទុក្ខា ។
៣៦៧-ផ្អូកផ្អើះទង្គិះគិត អួលអាណិតផ្តីអាត្មា
ក្សឹកក្សួលក្តួលក្តៅផ្សារ ស្មើរមរណាជីវិតប្រាណ ។
៣៦៨-ដំណើរដំណែងកាព គិតរៀងរាបតាមដោយដាន
តំណាលកាលយួនបាន គិតសម្លាប់ស្នងនោះឯង ។
៣៦៩-សង្ខេបទុកត្រឹមនេះ និងរករិះរកចាយចែង
និយាយស្រាយតែង ពីសិលសង្ឃក្នុងរាជនោះ ។
៣៧០-បទកាក្តិតែង តំណើរដំណែង តំណាលកាលនោះ
នគរកើតហេតុ ភិនភេទក្រគ្រោះ មានស្មូមួយឈ្មោះ
ហៅអ្នកភិក្ខុកែរ ។
៣៧១-ហើយមានមនុស្សម្នាក់ ចូលទៅពឹងពាក់
បួសជាសម្នេរ នេននោះឈ្មោះកុយ ប្រថុយខ្លួនតែ
តាមអ្នកភិក្ខុកែ ឥតឯមានឃ្លាត ។
៣៧២-តែងជាអ្នកថ្មី នាំនេនកុយដើរ គិតដោយសង្ងាត
រករៀនសីលសៃ សព្វថ្ងៃខ្មីឃ្មាត នេនកុយសង្ងាត
ចេះចាំជាក់ស្ទាត់ ។
៣៧៣-ដើរដល់ស្រុកណា បាសកសិការ មូលមករកគាត់
ទោះមានបើឈើ ជម្ងឺតម្កាត កាន់ទ្រួយដល់មាត់
ជម្ងឺសះសាន្ត ។
៣៧៤-ទោះទាំងលោកិយ ចោលខ្យល់ថ្មីៗ
សិងសះស្រាកស្រាន្ត សារពើរោគា យាយីក្នុងប្រាណ
សោតសិងសះសាន្ត ឥតឯអំពល់ ។ (**នៅមានត**)

# អ្នកតាបាពាល(១) ឬ "ព្រះកន្លោង"

***ដកស្រង់ចេញពីសៀវភៅ* ប្រជុំរឿងព្រេងខ្មែរ *នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរភាគ ៨ របស់* ពុទ្ធសាសនបណ្ឌិត្យ**

នៅជើងភ្នំបាពាល ក្នុងស្រុកស្វាយទង ខេត្តចូវដុក (មាត់-ជ្រូក) ដែនកូសាំងស៊ីន មានអ្នកតាមួយសំខាន់ជាងគេ ហៅថា អ្នកតាបាពាល ឬព្រះកន្លោង ។

តាមធ្លាប់បានដឹងឮពីដើមរៀងមក អ្នកស្រុកជុំវិញភ្នំនេះធ្លាប់ធ្វើវណ្ដាប់សែនអ្នកតានៅក្នុងរវាងខែពិសាខ ជេស្ឋ អាសាធ ឬស្រាពណ៍ មិនកំណត់ ប៉ុន្តែ ១ ឆ្នាំគេធ្វើតែម្ដងទេ ។

ឯរូបរាងអ្នកតានេះពុំមានទេ មានតែថ្មភ្នំ ១ ដុំធំ ដែលបណ្ដាជនលើកមកដាក់សន្មត់ជារូបអ្នកតា នៅរហូតមកដល់សព្វថ្ងៃនេះ ។ តែដល់ខែដូចមានរៀបរាប់ខាងលើនេះហើយ បណ្ដាជនជិតខាងប្រមូលរូបរួមលុយកាក់គ្នា ផ្សំនឹងប្រាក់រាជការផ្ដល់មកជួយខ្លះរាល់ឆ្នាំផង ដើម្បីទិញគោ ស្រា បាយ រៀបចំធ្វើជម ពៃ សង្ឃឹក ភ្លេងពិណពាទ្យ ភ្លេងខ្មែរប្រគុំ ច្រៀងរាំតាមទំនៀម មានបញ្ជាន់រូបប្រុសម្នាក់អង្គុយទទូរកន្សែងក្រហម ។ កាលបើអ្នកតាចូលហើយ រូបនេះធ្វើឫកពាហាក់ដូចជាអ្នកខ្លាំងពូកែមានឥទ្ធិឫទ្ធិ ទាយក៏ឆុត អ្នកស្រុកសួរការអ្វីនីមួយ ៗ អ្នកតានិយាយមិនឲ្យខ្វោះ ជួនជាឆ្នាំណារាំងឫសគ្មានទឹកធ្វើស្រែ អ្នកស្រុកក៏បន់ស្រន់ធ្វើបុណ្យសុំភ្លៀងអ្នកតា ៗ ក៏បណ្ដាលឲ្យមានភ្លៀងធ្លាក់ក្នុងវេលានោះដូចបំណងមែន ។

*អំពីប្រវត្តិ* ៖ តាមពាក្យនិយាយត ៗ គ្នាមកថា កាលពីដើមភ្នំបាពាលនៅជាកោះតូចមួយនៅឡើយ ស្ដេចពាលមួយអង្គ និងឧបរាជម្នាក់ជាប្អូនបង្កើត សុទ្ធតែជាអ្នកមានឫទ្ធិចេស្ដាខ្លាំងពូកែមកនៅទីកោះនោះ ។ ស្ដេចពាលជាបងធ្វើលំនៅក្នុងព្រៃដុបមួយ ឯឧបរាជជាប្អូននៅក្នុងដុបមួយផ្សេងពីគ្នា បានសេចក្ដីសុខសាន្តឥតមានសត្រូវណាហ៊ានបៀតបៀនឡើយ ។

ឧបរាជជាប្អូន មានចិញ្ចឹមសត្វក្រពើមួយធំសម្បើម នៅក្នុងអន្លង់បារ៉ាច ខេត្តឡុងស្វៀង ដែនកូសាំងស៊ីន ដើម្បីជាយានជំនិះជើងទឹក ។ ដោយបានឮល្បីថា នៅពាមអន្លង់បារ៉ាចមានក្រពើមួយកាចសាហាវណាស់ កាល់ទូក គោះខាំមនុស្សអស់ជាច្រើន ស្ដេចពាលយល់ឃើញការមិនស្រួលនឹងទុកក្រពើនេះ ទើបគិតថា បើសិនជាទុកឲ្យនៅយូរទៅ វានឹងបំផ្លាញជីវិតមនុស្សជាច្រើនទៀត ពុំលែងឡើយ ដូច្នេះគួរតែសម្លាប់វាចោល ។

នឹកដល់ក្រពើអន្លង់បារ៉ាច ស្ដេចពាលអាណិតដល់រាស្ត្រ ។ ថ្ងៃមួយក៏កាឡាខ្លួនជាលោកនេន ១ អង្គ និមន្តសំដៅទៅអន្លង់បារ៉ាចប្រាថ្នានឹងប្រយុទ្ធសម្លាប់ក្រពើរបស់ឧបរាជជាប្អូនឲ្យផុតជីវិត ។ លុះដើរបានបន្តិចក៏ជួបនឹងតាយាយចាស់កំពុងអុំទូកតូចមួយ សាមណេរក៏សួរថា ៖ "តាយាយអញ្ជើញទៅណាមកណា ?" តាយាយឆ្លើយ ៖ "ទៅបារ៉ាច" សាមណេរឮដូច្នោះ ក៏សុំតាយាយដោយសារទូកនោះទៅ ។ ទៅដល់ពាមបារ៉ាច សាមណេរឃើញអន្លង់មួយយ៉ាងធំ ក៏គិតឧបាយប្រាប់តាយាយនោះថា ៖ អាត្មាចុះស្រង់ទឹកត្រង់នេះបន្តិចសិន ចូរតាយាយអូសទូកឡើងលើគោករង់ចាំអាត្មាផង" ថាតែប៉ុណ្ណោះ សាមណេរចុះទៅក្នុងទឹក កាឡាខ្លួនជាក្រពើមួយធំ ពាទ៍ខ្វារខ្វ័រ ហែលយ៉ាងប្រញាប់ទៅរកក្រពើបារ៉ាចបានជួបភ្លាម ក៏តាំងប្រយុទ្ធគ្នាយ៉ាងគគ្រឹកគគ្រេង កើតជារលកទឹកធំ ៗ លិចទូក-ក្ដារអ្នកដំណើររតាត់រតាយអស់ ។ ក្រពើទាំងពីរប្រយុទ្ធគ្នា តាំងពីព្រឹករហូតដល់ថ្ងៃរសៀល ក្រពើបារ៉ាចចាញ់ក៏រត់ដោះដៃ ស្ដេចពាលក៏ត្រឡប់មកកោះវិញ ។ ឯក្រពើបារ៉ាច ដោយត្រូវរបួសធ្ងន់ ព្រមទាំងខឹងចិត្តនឹងប្រយុទ្ធមិនឈ្នះគេផង ខំវាឡើងលើគោក ហើយដេកស្លាប់នៅក្រោមដើមឈើមួយធំ មានម្លប់សាខា នៅក្បែរមាត់ច្រាំងអន្លង់បារ៉ាចនោះទៅ ។ ឧបរាជបានឮដំណឹងថា ក្រពើសេនាខ្លួនត្រូវស្ដេចពាលជាព្រះរាមសម្លាប់ដូច្នេះហើយ ក៏ប្រញាប់មករកមើល ឃើញក្រពើដេកស្លាប់នៅក្រោមដើមឈើមែន ក៏ប្រមូលអស់បណ្ដារាស្ត្រ មកជួយកាត់យកតែក្បាល ហើយសង់ខ្ទមមួយនៅទីនោះធ្វើបុណ្យ យកក្បាលក្រពើដាក់ក្នុងខ្ទម តម្កល់ទុកជាតំណាង ឲ្យបណ្ដាជនមើលដរាបមក ។ លុះយូរអង្វែងក្រោយមក ក្បាលក្រពើក៏ពុករលួយអស់ទៅ បណ្ដាជនក៏យកឈើមកឆ្លាក់ធ្វើឲ្យដូចជាក្បាលក្រពើមុន យកទៅតម្កល់ដូចដើមទុករហូតមកដល់សព្វថ្ងៃនេះ ។

ស្ដេចពាល និងឧបរាជ នៅជាសុខសប្បាយលើកោះនោះឥតមានទាស់ទែងគុំនុំប្រកាន់ខឹងនឹងគ្នា ដោយប្រការអ្វីសោះឡើយ លុះត្រាតែកោះតូចនោះដុះដាលខ្ពស់បានជាភ្នំ ។ លុះស្ដេចពាលចាស់ជរា ដឹងខ្លួនថាមុខជាមិនបានរស់យឺនយូរទៅទៀតទេ ក៏ហៅឧបរាជប្អូនមកប្រាប់ថា ៖ យើងមានឫទ្ធិចេស្ដាខ្លាំងពូកែលើភ្នំនេះ បើឥតអំពីបងទៅ ចូរប្អូននិងអកយាយ ព្រមទាំងបណ្ដាជនគិតធ្វើអ្វីមួយជាកេរ្តិ៍ទុកឲ្យអ្នកក្រោយ ៗ គេបានដឹងបានស្គាល់ឈ្មោះយើងផង កុំបីខានឡើយ ។

អំណឹះអំពីស្ដេចពាលទៅ ឧបរាជជាប្អូននៅគ្រប់គ្រងរក្សាទីនោះ ហើយយកថ្មមួយដុំ មកសន្មតទុកជាតំណាងស្ដេចពាល ប្រាប់បណ្ដាជនឲ្យជួយធ្វើជាសាក្សីទៅថ្ងៃក្រោយ ។

ស្ដេចពាលស្លាប់ទៅ ទៅកើតជាអ្នកតាភ្នំនៅរក្សាដុំថ្ម ដែលឧបរាជជាប្អូននិងបណ្ដាជនសន្មតទុកជាតំណាងដល់សព្វថ្ងៃនេះ ។

ឧបរាជជាប្អូន ក្រោយពីនោះ ក៏ស្លាប់ទៅទៀត ហើយទៅកើតជាអ្នកស្រុកបារ៉ាច នៅថែរក្សាក្បាលក្រពើរហូតមក ៕

---

*១-ឯកសារនេះលេខ ៥៦០៣២ រៀបរៀងដោយលោក ម៉ូវ សែម អភិបាលខេត្ត ថាញ់អ៊ី ស្រុកស្វាយទង ខេត្តចូវដុក កូសាំងស៊ីន ។*

**កំណាព្យ**

# ទឹកភ្នែកខ្មែរក្រោម

នេះគឺរឿងពិតឥតមានពីរ
រស់រងទារុណហួសពណ៌នា
ខ្មែរក្រោមសែងលីឃ្លាំងវេទនា
ជីវិតរងាពន់ពេកក្រៃ ។

ពេលប្រកបកម្មគេហៅប្រើ
ហើយស្រេចវាយវាត់ឥតប្រណី
រួសរាយស្មោះស្មើហាក់មេត្រី
សំដីជូរល្វីងអសប្បុរស ។

គ្រាបានចំណីលាក់បំពួន
ឯក្រពះខ្មែរស្ថិតក្រៀមផ្អួស់
គេចកែដោះខ្លួនចំអែតពោះ
សាច់ឈឺសព្វសុសពេញរាងកាយ ។

ស្លាកស្នាមរំពាត់ជិតរវាម
ខោអាវស្លៀកពាក់ដាច់រយ៉ៃ
ដាច់ស្បែកហូរឈាមរៀងរាល់ថ្ងៃ
មានថ្ងៃដាច់បាយហូបនំផ្អូម ។

ឈឺថ្កាត់ម្តង ៗ គ្មានថ្នាំផឹក
ខ្លះទៀតរអត់គេហ៍រេដេកខ្ទម
ផ្ទះដាចគ្មានស្លឹកបាំងលើក្រោម
សុខភាពទ្រុឌទ្រោមបាត់កម្លាំង ។

ជីវិតរាស្ត្រខ្មែរសែនតោកយ៉ាក
ភ្នែកខូងដូចខ្មោចកាយស្លេកស្លាំង
រស់ដោយលំបាកស្មើរមរណំ
ស្គមស្គាំងនៅតែគំរោងឆ្អឹង ។

ទឹកភ្នែកខ្មែរក្រោមហូរឥតដាច់
ប្រើច្បាប់ផ្តាច់ការមហាតឹងរឹង
ព្រោះម្ចាយកំណាចមឹងស៊ីមឹង
ស៊ូទ្រាំខំប្រឹងទាំងត្រដរ ។

ប្រវត្តិទុក្ខធំសង្គមខ្មែរ
ដីកេរខ្មែរមានបែរជាក្រ
ជីវិតឥតម៉ែទុក្ខវ័ណ្ឌក
ឆ្នាំងគ្មានអង្ករហោប៉ៅផត ។

ជីវិតខ្មែរក្រោមសែនខ្លោចផ្សា
កណ្តែងកណ្តោចក្នុងវាលវដ្ត
លើភពអន្ធិកាមហាកំសត់
រងចាំថ្ងៃផុតទុក្ខទារុណ ។

ឱះឱ! អនិច្ចាខេមរជាតិ
ផុតក្រញាំព្រាយចោរទុរជន
ថ្ងៃណារវាតឃ្លាតចាកពន្ធន៍
បានសុខសោភ័នដូចសិប្បា ។

ប៉ុន្តែបើខ្មែរចាំភពព្រេង
នោះពិតជាខ្មែររឹតខ្លោចផ្សា
ហើយហែកគ្នាឯងគ្មានអវសាន
គ្មានថ្ងៃណាសុខស្ងប់ឡើយ ។

ព្រោះថាទន្សោងម្រឹគបក្សា
ពិតជាមិនបានភោគ្គាឡើយ
បើរាជសីហាមិនស្វែងហើយ
ចម្លើយថាស្លាប់ទៀងប្រាកដ ។

ដូច្នេះបើខ្មែរប្រាថ្នាសុខ
ត្រូវពង្រឹងស្មារតីអំណត់
ឆ្លងផុតពីទុក្ខនឹមចក្រពត្តិ
សាមគ្គីផាត់ទាត់ចោរស្រែកឈាម ។

ហើយលាងជម្រះក្អួតកម្អែ
បើខ្មែរផុតគ្រោះជ្រោះស្ទឹងឈាម
ឬកទូលកញ្ឆែឆ្អែតឧត្ដម
សុខស្ងប់លែងបៀមទុក្ខទៀតអើយ ៕

# យុទ្ធសាស្ត្រថ្មីរបស់យួននៅលើមាតុភូមិកម្ពុជាក្រោម

កាលពីថ្ងៃទី ១០-២១ ឧសភា គ.ស. ២០០៤ សហព័ន្ធខ្មែរកម្ពុជាក្រោម បានធ្វើសេចក្ដីថ្លែងការណ៍ចំនួន ៧ ប្រធានបទគឺ ៖

១-ប្រធានបទស្ដីអំពីសិក្សាធិការ

២- ប្រធានបទស្ដីអំពីវប្បធម៌ និងសាសនា

៣- ប្រធានបទស្ដីអំពីសុខមាលភាព

៤-ប្រធានបទស្ដីអំពីបរិស្ថាន

៥-ប្រធានបទស្ដីអំពីសិទ្ធិមនុស្ស

៦-ប្រធានបទស្ដីអំពីស្ត្រីជនជាតិដើម

៧-ប្រធានបទស្ដីអំពីសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គមនៅឯវេទិកាអចិន្ត្រៃយ៍នៃអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉កសហរដ្ឋអាមេរិក ។

ក្រោយពេលដែលអំពើប្រល័យពូជសាសន៍ បទរំលោភសិទ្ធិមនុស្ស និងការបំផ្លិចបំផ្លាញវប្បធម៌ខ្មែរកម្ពុជាក្រោម កើតឡើងពីអំពើប្រព្រឹត្តរបស់យួន ត្រូវបានលាតត្រដាងពីភពអាថ៌កំបាំងកប់យ៉ាងជ្រៅជាយូរឆ្នាំទៅហើយនោះឲ្យឮខ្ទរខ្ទាពេញសកលលោក យួនក៏បានផ្លាស់ប្ដូរនយោបាយប្លន់ដី បន្តធ្វើអាណានិគមមកលើជាតិមាតុភូមិខ្មែរកម្ពុជាក្រោមតាមយុទ្ធសាស្ត្រថ្មីដែលហៅថាសង្គ្រាមខេមរូបនិយកម្ម ។

យួនបានដាក់ឈ្មោះថ្មីដល់ខ្មែរកម្ពុជាក្រោម បង្ខំឲ្យខ្មែរកម្ពុជាក្រោមហៅខ្លួនឯងថា ខ្មែរណាមបោ នៅប្រទេសវៀតណាម ។ យួនបានបំផុសប្រជាជាតិខ្មែរក្រោម ដែលកំពុងរស់នៅក្នុងមាតុភូមិក្រោមអាណានិគមរបស់យួននោះ ឲ្យប្រឆាំងចំពោះខ្មែរកម្ពុជាក្រោមនៅគ្រប់ទីកន្លែងទូទាំងសកលលោក និងក្នុងមាតុភូមិដែលកំពុងធ្វើសកម្មភាពទាមទាសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងនោះថា ជាខ្មាំង ជាពួកប្រតិកិរិយាខ្មែរក្រោម ចង់បំបែកបំបាក់មិត្តភាពខ្មែរ-គិញ-ហ្វា ។ យួនបានប្រើប្រាស់ខ្មែរកម្ពុជាក្រោមឲ្យចេញមុខកម្ទេចខ្មែរគ្នាឯង ជាក់ស្ដែងកាលពីចុងខែមិនា គ.ស.២០០៥ យួនបានបញ្ជាព្រះតេជគុណ សុខ សាន្ត អនុគណខេត្តព្រះត្រពាំង និងព្រះតេជគុណថាច់ សាងធឿង ឲ្យចាប់ព្រះសង្ឃខ្មែរទាំងឡាយណា ដែលបានទំនាក់ទំនងជាមួយសហព័ន្ធខ្មែរកម្ពុជាក្រោម ផ្សព្វផ្សាយព្រឹត្តិប័ត្រ និង CD ចម្រៀងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ។ និងកាលពីថ្ងៃទី ៥ មេសា គ.ស.២០០៥ យួនបានរៀបចំមហោស្រពសិល្បៈជនជាតិដើមដែលប្រារព្ធនៅខេត្តព្រះត្រពាំង យួនបានប្រើប្រាស់វេទិកានោះ បំផុសកំហឹង និងថ្កោលទោស ចំពោះខ្មែរក្រោមអ្នកស្នេហាជាតិ ដែលមានសម្លេងដើមទាំងស្រុងរបស់យួនដូចតទៅ ៖....

ក្នុងពិធីនោះ យួនបានប្រើប្រាស់ខ្មែរកម្ពុជាក្រោមឲ្យច្រៀង-រាំបង្អួតមតិជាតិ និងអន្តរជាតិថា ខ្មែរនៅកម្ពុជាក្រោម ដែលយួនហៅថាខ្មែរណាមបោនោះ មានសិទ្ធិសេរីភាពពេញបរិបូណ៌ខាងផ្នែកវប្បធម៌ ។

ទង្វើរបស់យួនទាំងអស់នេះ គឺជានយោបាយបំភ័ន្តមតិជាតិ និងអន្តរជាតិ ក្នុងបំណងបញ្ចៀសឲ្យផុតអំពីពាក្យថា **យួនធ្វើអាណានិគមមកលើជាតិមាតុភូមិខ្មែរកម្ពុជាក្រោម** ជាផែនការពន្យាពេលដំណើរនយោបាយអហិង្សារបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងការទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ដើម្បីយួនយកពេលបណ្ដុះបណ្ដាលមនុស្សជនជាតិយួន ទាហានយួន នគរបាលយួន មន្ត្រីយួនឲ្យរៀនភាសាខ្មែរ សំរាប់បន្តនយោបាយធ្វើអាណានិគមមកលើខ្មែរកម្ពុជាក្រោមតាមរបៀបដណ្ដើមអាសនៈ នៅលើវេទិកាអន្តរជាតិ-សេដ្ឋកិច្ចនៃធនធានធម្មជាតិរបស់ខ្មែរ នយោបាយ និងអំណាចត្រួតត្រាក្នុងស្ថាប័នជាតិខ្មែរកម្ពុជាក្រោម នៅពេលដែលអង្គការសហប្រ-ជាជាតិ ចូលមកគ្រប់គ្រងទឹកដីខ្មែរកម្ពុជាក្រោមនាអនាគតនោះ ។ ប្រសិនបើយួនមានបំណងល្អចំពោះខ្មែរកម្ពុជាក្រោមមែន **យួនត្រូវតែបញ្ឈប់បញ្ហាជាឧបស័គ្គរបស់ខ្មែរកម្ពុជាក្រោម ៦ យ៉ាងជាបន្ទាន់ ៖**

១-យួនត្រូវតែឈប់កែច្នៃប្រវត្តិសាស្ត្រ ភូមិសាស្ត្រខ្មែរកម្ពុជាក្រោម គឺឈ្មោះភូមិ-ឃុំ-ស្រុក-ខេត្ត-ប្រទេស ដែលយួនហៅជាភាសាយួននោះ ត្រូវហៅជាភាសាខ្មែរវិញ ប្រវត្តិរបស់យួននៅលើទឹកដីខ្មែរក្រោម ត្រូវប្រកាសប្រាប់ប្រជាជនយួន និងប្រជាជនក្នុងពិភពលោកឲ្យដឹងថា យួនបានចូលមកឈ្លានពានធ្វើអាណានិគម មកលើជាតិ-មាតុភូមិខ្មែរកម្ពុជាក្រោម មិនត្រូវនិយាយថា យួនចូលមកកាប់ឆ្ការកាន់កាប់បើកទូលាយមក ក្នុងទឹកដីភាគខាងត្បូង ដែលយួនហៅថា **ណាំបោ ឬណាមគី** ជាទឹកដីរបស់យួន ឬស្ដេចខ្មែរប្រគល់ទឹកដីឲ្យជាការតបគុណនោះឡើយ ព្រោះថាគ្មានព្រះមហាក្សត្រខ្មែរអង្គណាពីអតីតកាល ឬក៏បច្ចុប្បន្ននេះ កាត់ទឹកដីទៅឲ្យយួនសូម្បីតែមួយចំអាមនោះឡើយ ។

២-ធនធានសេដ្ឋកិច្ច នៅលើមាតុភូមិខ្មែរកម្ពុជាក្រោមទាំងអស់ត្រូវប្រគល់មកឲ្យខ្មែរធ្វើអាជីវកម្មវិញ ។

៣-ភាសាខ្មែរ អក្សរខ្មែរ ត្រូវឲ្យខ្មែរប្រើប្រាស់ជាផ្លូវការនៃស្ថាប័នរបស់រដ្ឋនៅក្នុងមាតុភូមិរបស់ខ្លួន វប្បធម៌ខ្មែរ និងព្រះពុទ្ធសាសនា ត្រូវលើកតម្កើង មិនត្រូវកែច្នៃជាដាច់ខាត ។

៤-ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មិនត្រូវកាត់បន្ថយដោយការជន្លៀសទាំងបង្ខំ សម្លាប់ដោយអាថ៌កំបាំង ចោទដាក់ទោស ធ្វើទារុណកម្មដល់ស្លាប់ និងការបំបាត់តាមការកំណត់គោត្តនាមនោះឡើយ ។

៥-ជំនួយអន្តរជាតិត្រូវចែករំលែក ដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមឲ្យបានត្រឹមត្រូវ រួមទាំងការថែទាំផ្នែកសុខមាលភាពផង។

៦-ត្រូវផ្ដល់សិទ្ធិសេរីភាពដល់ខ្មែរកម្ពុជាក្រោម ដូចដែលមានចែងក្នុងច្បាប់អន្តរជាតិ គឺមានសទ្ធិ សេរីភាព ប្រជាធិបតេយ្យ

## វេទិកា គំនិតជាតិ

ក្នុងជីវភាពនយោបាយ ជីវភាពស្មារតី ជីវភាពសម្ភារៈគ្រប់ផ្នែក និងគ្រប់វិស័យទាំងអស់ មានសេរីភាព ចាត់តាំងគណបក្សនយោបាយ ចាត់តាំងសមាគម ចាត់តាំងសហជីព និងអង្គការមហាជន ផ្សេងៗ សេរីភាពខាងការបញ្ចេញមតិ សរសេរ បោះពុម្ពផ្សាយ ធ្វើបាតុកម្ម ធ្វើកូដកម្ម ទាក់ទងសំបុត្រស្នាម ដើរហើរ ស្នាក់នៅ ។ល។

*និងត្រូវគោរពឲ្យបានដាច់ខាតនូវកម្មវត្ថុពិសេស ២ យ៉ាង របស់ខ្មែរកម្ពុជាក្រោមគឺ ៖*

១-យួនត្រូវដកអាណានិគមចេញពីមាតុភូមិខ្មែរកម្ពុជាក្រោម ដែលមានទំហំ ៦៨៦០០ គីឡូម៉ែត្រក្រឡា គឺស្ថិតនៅភាគខាងត្បូងទេសវៀតណាមបច្ចុប្បន្ន ។

២-ដាក់ទឹកដីខ្មែរកម្ពុជាក្រោម នៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ តាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ជំពូកទី ១១-១២-១៣ ដើម្បីបង្កើតឲ្យមានបរិយាកាសនយោបាយសេរី និងបរិសុទ្ធភាពសម្រាប់ខ្មែរកម្ពុជាក្រោម អនុវត្តសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ៕

*ថាច់ សុរិន្ទ*

# ការទាមទារយ៉ាងទទូចរបស់ខ្មែរម្ចាស់ដី

រាល់ការបរិយាយខាងក្រោមនេះ វាដូចជាសាំបន្ទិចមែន ។ ប៉ុន្តែជាមេរៀន ដែលខ្មែរម្នាក់ ៗ ត្រូវស្វែងយល់ ហើយធ្វើការស្វ័យសម្រេច ដោយខ្លួនឯងចំពោះជោគវាសនា នៃប្រទេសជាតិខ្លួន ។

តាមលំអាននៃប្រវត្តិសាស្ត្រ កម្ពុជាជាចក្រភព ដ៏ធំល្វឹង-ល្វើយ ។ ព្រំប្រទល់ខាងជើង លាតសន្ធឹងទល់ខេត្ត យូណាន ប្រទេសចិន ។ ខាងត្បូងទល់ជ្រោយម៉ាឡាយូ ។ ខាងលិចទល់ភូមា និងខាងកើតទល់សមុទ្រ ។

ចំណេរក្រោយមក ពួកអនារ្យជន យួន សៀម ជាអាទិ៍ ពួកនេះមានមហិច្ឆតា ជាចក្រពត្តិវាតទីនិយម និងល្បិចកលដ៏ពឹសពុល បំបែកបំបាក់ផ្ទៃក្នុងខ្មែរ ឱ្យខ្មែរកើតមាននូវសង្គ្រាម កាប់សម្លាប់គ្នាឯងឥតស្រាក ។ រីឯពួកអនារ្យជនទាំងនោះ ចាំតែទទួលផលចំណេញ ដោយរស់សោយសុខលើគំនរទុក្ខរាស្ត្រខ្មែរយ៉ាងរំភើយ ។ អំពើជួជាតិរបស់ចោរ យួន សៀម បានធ្វើឱ្យខ្មែរធ្លាក់ចុះឱនភាពស្ទើរគ្រប់វិស័យ ។ ឯទឹកដីទៀតសោត ក៏បាត់បង់ រៀវរួញឥតឈប់ ។ អ្វីដែលនៅសល់នោះ គឺអត្តសញ្ញាណ "ខ្មែរលើ, ខ្មែរក្រោម" តែប៉ុណ្ណោះ ។

ក្នុងចំណោមពួកប្រតិកិរិយាខាងលើ យើងសូមលើកយកអំបូរគ្មានកំណើតយួនមួយមកនិយាយ ។ ឈ្មោះថាយួននេះ គឺមានគំនិតលេបទឹកដីគេឯងប្រមាណ ៥ សតវត្សរ៍មកហើយ ។ ជាក់ស្តែងកាលក្នុងគ.ស. ១៦៩៦ ក្រុមដូនតាអាវាត់អាវាយយួន ស៊ីដាច់ប៉ាត់នគរចំប៉ា ។ ធ្វើឱ្យបងប្អូនចាម គ្មានទឹក គ្មានដី លុះសព្វថ្ងៃ ។

យួននេះជាជាតិជួជង គ្មានស្គាល់បុណ្យ គុណ ទោស អ្វីឡើយ ។ ដោយហេតុថា ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ២ ស្តេចក្រុងវ៉េ បានយកបុត្រីព្រះនាមអង្គចូវ ឬ កូជិន ថ្វាយព្រះបាទជ័យជេដ្ឋាទី ២ ។ កាលនោះ ស្តេចខ្មែរទ្រង់មានទឹកព្រះទ័យសន្តោសមិនប្រកាន់និន្នាការជាតិជាសត្រូវ សួពូជអ្វីឡើយ ។ មិនតែប៉ុណ្ណោះទ្រង់បានលើកស្នួយព្រះនាងអង្គចូវ ជាមហេសីពេញច្បាប់នៃព្រះនគរទៀតផង ។

អំពើល្អរបស់ស្តេចខ្មែរ ត្រូវបានស្តេចយួនជាន់ឈ្លី ហើយកាឡៃថា ជាជោគជ័យលើផ្នែកកលល្បិច (យកស្រីជាផ្ទាក់) របស់ខ្លួន (យួន) ទៅវិញ ។ ចាប់តាំងពីពេលនោះមក យួនចូលលុកលុយ ធ្វើទុក្ខបុកម្នេញខ្មែរក្រោម ដោយប្រើល្បិចកលគ្រប់រូបភាព។

យើងដឹងហើយថា យួនធ្វើយួនឧបនិយកម្មលើ ខ្មែរតាំងពីរាជព្រះចៅ មិញ ម៉ាង រហូតដល់ព្រះចៅ យ៉ា ឡុង (ស្តេចយួន) មកម្ល៉េះ ។ ពិសេស គឺនៅកម្ពុជាក្រោម ពួកយួនចាប់ផ្តើម ផ្លាស់ប្តូរឈ្មោះខេត្តពីខេមរភាសាមកជាភាសា ដែលគ្មានឫសគល់របស់យួនទៅវិញ ។ តែអ្វីដែលយើងនៅរក្សាបានមកទល់ពេល នេះអាស្រ័យដោយកម្ពុជាក្រោម លោកមានឆ្នើមជនគ្រប់ជំនាន់ ក្រោកឡើងតស៊ូប្រឆាំងនឹងអាណានិគមយួន រហូតដល់ហ៊ានបូជាជីវិត តួយ៉ាងឧកញ៉ា ស៊ឺនគុយ ជាដើម ។

ដើមហេតុបណ្តាលឱ្យខ្មែរ មិនអាចត្រជាក់ចិត្ត នឹងយួនបានដោយសារយួននេះ ធ្លាប់មានប្រវត្តិកាប់សម្លាប់ខ្មែរ យ៉ាងព្រៃផ្សៃបំផុតដូចជាសម័យ ទ្រៀង មិញ យ៉ាង យួនបានយកខ្មែរ ដែលយួនចាត់ទុកជាទាសករ ព្រែកជីកវិញតេ មកកប់ទាំងរស់ដោយមានសណ្ឋានជាមុមជើងក្រាន ដាក់ខ្ទះដុតភ្លើងដាំតែអុង ។ ពេលជីកព្រែករួចហើយយួនបានយកឃ្នាងមកដាក់គាបកខ្មែរ ក្នុងឃ្នាងមួយ ៗ ប្រមាណពីដប់ទៅម្ភៃនាក់ ។ រួចយួនបង្ហូរទឹកសមុទ្រចូលបណ្តាលឱ្យ ខ្មែរស្លាប់នឹងលង់ទឹកអស់មួយការដ្ឋានជីកព្រែក ។

មកដល់សម័យខ្មោច ហូ ជីមិញ(១៩៤៥-៤៦) យួនកុម្មុយ-និស្ត យួនបានបញ្ឆោតខ្មែរ ឱ្យចូលក្នុងឃ្លាំងស្រូវ ដោយយកលេសថាលោកធំយួនមកប្រជុំ ដើម្បីដោះស្រាយតាមការទាមទារនូវសិទ្ធិសេរី-ភាពរបស់ខ្មែរ ។ តែផ្ទុយវិញ យួនបានចាក់សោទ្វារពីខាងក្រៅជាប់ហើយចាក់សាំងដុតខ្មែរទាំងរស់ ។ ហេតុការណ៍ដ៏រន្ធត់នេះ គ្រាន់តែខ្មែរជាអ្នកភូមិផ្ទោរអណ្តែតមួយ ស្លាប់ចំនួន ៤០ នាក់ ។ សម្រែកខ្មែរមុននឹងដាច់ខ្យល់ស្លាប់ ដោយសារយួនដុតទាំងរស់ នៅតែឮគ្រលួច

ក្នុងសម្បជញ្ញៈកូនខ្មែរជានិច្ច ។

នៅមានករណីជាច្រើនទៀត ដែលយើងពុំបានរៀបរាប់នាពេលនេះ ។ ម្លឹង ៗ ហើយដូនតាខ្មែរ ពុំដែលផ្ដែផ្ដាំកូនចៅឱ្យចងអាឃាតនឹងយួនឡើយ ។

ក្នុងនាមខ្មែរជាពុទ្ធសាសនិក យើងមិនដោះស្រាយបញ្ហា តាមកំលាំងបាយឡើយ ។ ប៉ុន្តែ បើជនណា ប្រទេសណា នៅតែគឃ្លើនដោយគ្មានលក្ខណៈជាមនុស្សនោះ ខ្មែរមិនញញើតនឹងធ្វើពលីកម្មឡើយ ព្រោះការបូជាជីវិតក្នុងនាមជាម្ចាស់ គឺវាប្រសើថ្លៃថ្លាជាងងាប់ជាប់ឈ្មោះជាចោរគ្រប់ទំព័រនៃប្រវត្តិសាស្ត្រ ។ ការរៀបរាប់ខាងលើនេះ គឺមិនមានន័យថា យើងចាត់ទុកអ្នកដែលនៅជុំវិញខ្លួនសុទ្ធតែជាសត្រូវនោះទេ ។ ផ្ទុយវិញ ឬ និយាយដោយឡែក យើងខ្មែរស្រឡាញ់និងបន្តជួយយកអាសា ប្រជាជនស្លូតត្រង់យួន រហូតមកដល់សព្វថ្ងៃទៀតផង ។

`គ្រប់ឧបាយកល ពុំមែនប្រកបដោយជោគជ័យ នៅគ្រប់កាលនោះទេ !´ ។

សំរាប់ពេលនេះ មេដឹកនាំយួនគួរបោះបង់គំនិត ដ៏លាមកដែលជាផ្នត់គំនិតដូនតាខ្លួនចោលចេញទៅ ហើយងាកមកធ្វើល្អជាមួយអ្នកជិតខាងខ្លួន ដើម្បីឱ្យកូនចៅនៃយួនគ្មានរស់ស្មើមុខ ស្មើមាត់ដូចសាសន៍គេឯងផង ។ សូមមេដឹកនាំយួនកុម្មុយនិស្ដ កុំស្រមើស្រមៃថា ខ្មែរនៅតែស្ថិតក្រោមឱវាទខ្លួនជានិច្ចឱ្យសោះ ។ បើមានករណីដូច្នេះមែន វាគ្រាន់តែជាមួយដំណើរ ៗ ប៉ុណ្ណោះ ។ ព្រោះសន្ដាននៃខ្មែរ ពិតជាមិនចោលសាច់ ទៅស្រវាឆ្អឹងនោះទេ ។

ដើម្បីឱ្យម្ចាស់ដីមានប្រក្រតីភាពផ្លូវចិត្ត មេដឹកនាំយួនបច្ចុប្បន្នត្រូវតែពិនិត្យឡើងវិញ ឬ ដោះស្រាយជាបន្ទាន់ រាល់ការទាមទាររបស់ខ្មែរក្រោម រួមមាន ៖

- សិទ្ធិនយោបាយ សិទ្ធិពលរដ្ឋ
- សិទ្ធិគោរពជំនឿសាសនា ទំនៀមប្រពៃណីខ្មែរ
- សិទ្ធិសិក្សាអក្សរសាស្ត្រជាតិខ្មែរ
- សិទ្ធិទទួលបាននូវពត៌មានពីគ្រប់មជ្ឈដ្ឋាន
- សិទ្ធិទំនាក់ទំនងរវាងខ្មែរនិងខ្មែរទូទៅ
- សិទ្ធិទទួលបានការគាំពារផ្នែកសុខភាព ជីវភាព
- សិទ្ធិទទួលបាននូវសន្តិសុខសាធារណៈ សុវត្ថិភាពជាបុគ្គល និងសមធម៌ យុត្តិធម៌សង្គម ។

ការទាមទារខាងលើនេះ ប្រសិនបើមេដឹកនាំយួន បោះបង់នូវគំនិតដូនតាខ្លួនចោលនោះ អ្វី ៗ វាងាយស្រួលជាងបកចេកទៅទៀត ។ ប៉ុន្តែបើម្នាល មេដឹកនាំយួននៅតែបន្តមើលស្រាលរាល់ការទាមទារទាំងនេះ នោះយួននឹងត្រូវទទួលផលវិបាក ដែលមិនអាចស្មានទុកជាមុនបានឡើយ ។ តែបើយួនព្រមទទួលសាងនូវអំពើល្អ ជាមួយមនុស្សជាតិ ពិសេសគឺខ្មែរក្រោម នោះព្រលឹងដូនតានៃយួន ពិតជារួចផុតពីឋាននរកអវីចី ហើយនឹងបានមកសោយសុខ នាសុគតិភពជាក់ជាពុំខានឡើយ ៕

*អៀង សុផាត*

---

# សេចក្ដីជូនដំណឹង

p [ q

**-មិត្តសមាគមខ្មែរកម្ពុជាក្រោម -សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម -សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម**

*នឹងប្រារព្ធពិធីអបអរសាទរ ទិវាសហព័ន្ធខ្មែរកម្ពុជាក្រោម នៅលើវេទិកាអន្តការសហប្រជាជាតិ ។*

*-កម្មវិធីអបអរសាទរ ប្រព្រឹត្តទៅនៅវេលាម៉ោង ១៤ : ០០ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៥ ។*

*-ទីកន្លែងប្រារព្ធពិធី ៖ នៅវត្តសាមគ្គីរង្សី ដែលស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។*

*ព្រះវត្តមាន និងវត្តមានរបស់ព្រះតេជព្រះគុណ សម្ដេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គឺជាកិត្តិយសដ៏ថ្លៃថ្លាសម្រាប់ គណៈកម្មការរៀបចំអង្គពិធីនៃខ្មែរកម្ពុជាក្រោមទាំងមូល ។*




បញ្ញាសជាតក
រឿងទី ១៦

*ជាស្នាដៃនិពន្ធរបស់លោក **ញ៉ុក ថែម***

*បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩*

# រឿងកនកវណ្ណរាជ

មានសេចក្ដីដំណាលពីព្រេងនាយថា មានព្រះមហាក្សត្រមួយអង្គព្រះនាមកនកវណ្ណរាជ គ្រងរាជក្នុងកនកបិត្តនគរ មហេសីព្រះនាម កនកា ទ្រង់មានបុរោហិតម្នាក់ ចេះចប់ស្ទាត់ជំនាញក្នុងសិល្បសាស្ត្រទាំងពួង ។ ថ្ងៃ ១ ព្រះរាជាទ្រង់ត្រាស់សួរបុរោហិតនោះថា "លោកអាចារ្យ ក្នុងឆ្នាំនេះ តើមាននក្ខត្តឫក្សប្រែកបដោយសុខ ឬជាទុក្ខ ឬមួយកើតកលីយុគពុំជួរកាលយ៉ាងខ្លះ?"

បុរោហិតក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស ក្នុងឆ្នាំនេះ បានសេចក្ដីចម្រើនល្អណាស់ ប៉ុន្តែដល់កន្លង ១០ ឆ្នាំរាប់ពីឆ្នាំនេះទៅ នឹងកើតវិបត្តិដោយរាំងភ្លៀង អស់កំឡុង ១២ ឆ្នាំ គ្មានទឹកភ្លៀង ១ ដំណក់ស្រក់ដល់ដីឡើយ" ។

ព្រះរាជាទ្រង់ស្លុតព្រះហឫទ័យ ភិតភ័យព្រួយបារម្ភជាខ្លាំង ទ្រង់ព្រះចិន្ដាថា "ឱពួករាស្ត្រប្រជានឹងវិនាសអស់ហើយតើសម្ពូទីបនេះ នឹងសូន្យហើយតើ បើដូច្នេះ តើអាត្មាអញនឹងធ្វើដូចម្ដេច?" ទ្រង់ព្រះចិន្ដាដូច្នេះហើយ ត្រាស់ហៅអាមាត្រ ហើយទ្រង់បញ្ជាថា "ចូរអ្នករាល់គ្នាទៅឃោសនា ប្រាប់ពួករាស្ត្រប្រជាក្នុងជម្ពូទីបថា "អ្នកទាំងឡាយ ចូរខំខ្វល់ខ្វាយភ្ជួររាស់ស្ទូងស្រូវទាំងស្រែប្រាំង ស្រែវស្សា ទាំងទីទំនាប ទីទំនួល កុំបីឲ្យសល់បន្លោះត្រង់ណាឡើយ" ។

លុះកន្លងដល់ឆ្នាំទៅ ក៏រាំងភ្លៀងស្ងួតហួតហែងគ្មានទឹកភ្លៀងមួយដំណក់ស្រក់ដល់ដីឡើយ ។ ពួកមនុស្សក្នុងនគរក៏កើតទុក្ខព្រួយខ្លោចផ្សាដោយអត់អាហារខ្លាំង ក៏ស្គាំងស្គមទ្រមកម្លាំង ស្លាប់បាត់បង់អស់ក៏ច្រើន ។ មានពួកខ្លះផ្ដុំប្រមូលគ្នាធ្វើជាចោរប្លន់ដណ្ដើមអាហារគ្នាស៊ី ចំនួន ១០០ នាក់ក៏មាន ១០០០ ក៏មានទាំងប្លន់កាប់សម្លាប់គ្នាស្លាប់ដេរដាស់ក្នុងជម្ពូទីបធុំក្លិនអសោចិ៍សុទ្ធតែខ្មោច ដូចព្រៃស្មសានឋានស្ងាត់ ។

តមកថ្ងៃមួយ ព្រះបាទកនកវណ្ណរាជ ទ្រង់មានព្រះបន្ទូលប្រាប់ពួកអាមាត្ររបស់ព្រះអង្គថា "បើអ្នករាល់គ្នាចង់ចេញទៅនៅទីណា ៗ ក្ដី ចូរនាំបុត្រភរិយាទៅទីនោះ ៗ តាមបំណងរៀងខ្លួនចុះ" ។ ពួកអាមាត្យក្រាបទូលតបវិញថា "បពិត្រព្រះរាជសម្ភារ យើងខ្ញុំទូលបង្គំទាំងអស់គ្នា ពុំព្រមចេញទៅចោលព្រះអង្គទេ សុខចិត្តស្លាប់ក្រោមព្រះបាទាទាំងអស់គ្នា" ។ ព្រះរាជាមានព្រះទ័យសប្បុរសអង្គនេះ តែងទ្រង់ព្រះរាជទានស្រូវអង្ករដល់មហាជននឹងពួកអាមាត្ររបស់ព្រះអង្គរាល់ ៗ ថ្ងៃ ដរាបទាល់តែស្រូវអង្ករនៅសល់បន្តិចបន្តួច ទ្រង់ក៏បន្ថយ ទ្រង់ព្រះរាជទានអាហារដល់កូនអ្នកនគរ និងកូនអាមាត្រអស់បួនខែទៀត ។ ក្រោយបំផុតទ្រង់សំចៃទុកសម្រាប់ព្រះរាជបុត្រនឹងព្រះរាជទេពីបានត្រឹមតែមួយខែប៉ុណ្ណោះ ។

ខណៈដែលព្រះរាជា នៅសល់អង្ករត្រឹមមួយនាឡិ ព្រះរាជទេពីចំអិនទុកពុំទាន់បានសោយ ស្រាប់តែមានព្រះបច្ចេកពុទ្ធមួយអង្គនៅភ្នំគន្ធមាទន៍ ទើបតែចេញពីនិរោធសមាបត្តិ បានប្រមើលមើលសត្វលោកដោយទិព្វចក្ខុ ក៏បានជ្រាបច្បាស់ថាព្រះបាទកនកវណ្ណរាជជាពុទ្ធង្កូរ គួរអាត្មាអញចេញទៅសង្គ្រោះចំពោះព្រះរាជាអង្គនោះចុះ ។ ព្រះបច្ចេកពុទ្ធក៏ហោះធ្បានតាមផ្លូវអាកាស ហើយបានចុះក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ៗ បានទតឃើញព្រះបច្ចេកពុទ្ធមានបាត្រទទេដូច្នេះ ក៏ទ្រង់ជ្រាបថា "លោកម្ចាស់អង្គនេះប្រាកដជាត្រូវការបង្ហាន់បិណ្ឌបាត បើអាត្មាអញកំសត់ទុគិតម្ល៉េះ តើនឹងធ្វើទានដូចម្ដេចកើត" ទើបទូលទៅលោកថា"លោកម្ចាស់ ខ្ញុំព្រះករុណាមានមាសប្រាក់ សំពត់អាវសារស្បៃច្រើនចំណែកអង្ករត្រឹមមួយនាឡិក៏គ្មានទេ" ។ ឯព្រះបច្ចេកពុទ្ធគង់នៅតែស្ងៀម ។ ទើបព្រះរាជាត្រាស់សួររាជបរិពាររបស់ទ្រង់ថា "អ្នកណាមួយបាយខ្លះដែរឬទេ?" ។ ព្រះរាជទេវីក្រាប

ទូលថា "ព្រះស្វាមី ! ខ្ញុំម្ចាស់បានចំអិនបាយចំនួនអង្ករមួយនាឡិទុកបម្រុងតែព្រះរាជកុមារ" ។ ព្រះរាជាសប្បុរសនោះ មានព្រះទ័យត្រេកអរណាស់ ទើបទ្រង់យកចំណែកព្រះស្ងោយរបស់ព្រះអង្គ ទ្រង់នាំយកទៅប្រគេនព្រះបច្ចេកពុទ្ធទាំងអស់ ទ្រង់មានបន្ទូលថា "បពិត្រលោកម្ចាស់ ចង្ហាន់បិណ្ឌបាត្រនេះ ទោះតិចក្តី ច្រើនក្តី ថោកទាបក្តី ថ្លៃថ្លាក្តី ខ្ញុំព្រះករុណាសូមថ្វាយព្រះអង្គដោយចិត្តសទ្ធាជ្រះថ្លា និងមនោសោមនស្ស សូមព្រះអង្គទទួលយកទាំងអស់កុំបីទើសទាល់ឡើយ" ។

ព្រះបច្ចេកពុទ្ធ បានធ្វើកត្តានុមោទនា ហើយបានហោះធ្យានតាមផ្លូវអាកាស ឆ្ពោះភក្ត្រសំដៅភ្នំគន្ធមាទន៍ ហើយឆាន់ចង្ហាន់នោះរួចស្រេចកាលណា មហាមេឃក៏បង្អុរភ្លៀងធំធ្លាក់ចុះមកគគុកគគាក់ឥតអាក់ ។ មហាជនបានក្រាបទូលព្រះរាជាថា "បពិត្រព្រះរាជសម្ភារ គួរអស្ចារ្យណាស់ មហាមេឃបង្អុរភ្លៀងធំមកក្នុងថ្ងៃនេះ ប្រាកដជាកើតឡើងដោយតេជៈផលទានរបស់ព្រះអង្គ" ។ ព្រះរាជាសប្បុរសត្រាស់ថា "មហាមេឃបង្អុរភ្លៀងធំយ៉ាងនេះប្រាកដជាកើតឡើង ដោយអនុភាពនៃព្រះបច្ចេកពុទ្ធទេតើ ! " ។

មុខគួរឲ្យអស្ចារ្យណាស់ មុនដំបូង មហាមេឃបង្អុរភ្លៀងធំជំរះវត្ថុមិនស្អាត វត្ថុសោចិ៍លើផែនដី បង្ហូរទម្លាក់ទៅក្នុងសមុទ្រ ហើយបង្អុរភ្លៀងផ្កានានា បង្អុរភ្លៀងសុទ្ធតែបង្អែមពួកមនុស្សនាំគ្នារើសបរិភោគ ។ តពីនេះមក បង្អុរអង្ករអស់ ៧ ថ្ងៃ ភ្លៀងស្រូវអស់ ៧ ថ្ងៃ សំលៀកបំពាក់អស់ ៧ ថ្ងៃ ប្រាក់ ៧ ថ្ងៃ មាន ៧ ថ្ងៃ ពេជ្រនិលចិន្តា ៧ ថ្ងៃ ។ កនកចិន្តាមហានគរក៏សម្បូណ៌សប្បាយចំរើនរុងរឿងល្អដូចឋានទេវលោកហោង ៕

# សេចក្តីថ្លែងអំណរគុណ

*ការិយាល័យប្រធានសភាព្រឹទ្ធាចារ្យ សូមថ្លែងអំណរគុណ ៖*

*-ព្រះចៅអធិការ ព្រះអង្គ ទ្រឿង សារុង (កាណាដា)*

*-ព្រះចៅអធិការ ព្រះអង្គ ទ្រឿង គីចន្ទា (រដ្ឋម៉ាសាជូសេត សហរដ្ឋអាមេរិក)*

*-លោក សឹង រតនៈ*

*-លោក សារុន យុស*

*ព្រះអង្គ និង អស់លោក បានឧបត្ថម្ភថវិកាដល់ការិយាល័យ ដើម្បីការិយាល័យប្រធានសភាព្រឹទ្ធាចារ្យ យកទៅជួយដល់តំណាងសហព័ន្ធប្រចាំនៅព្រះរាជាណាចក្រកម្ពុជា រៀបចំបុណ្យចូលឆ្នាំ ប្រពៃណីជាតិ ។*

*អាស្រ័យហេតុនេះតាងនាមប្រធានសភាព្រឹទ្ធាចារ្យ សូមប្រសិទ្ធិពរមហាប្រសើរចូរមានដល់ព្រះអង្គ និងអស់លោក សមាជិក-សមាជិកា កុំបីអាក់ខានឡើយ ៕*